# ក

# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៥-៣-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៣០៣/១០៥ ស្តីពីការតែងតាំងឯកឧត្តមវេជ្ជបណ្ឌិត **យឹម សំអឿន** ជាទីប្រឹក្សាប្រធានរដ្ឋសភា ទទួលបន្ទុកកិច្ចការសុខាភិបាល និងអភិវឌ្ឍន៍សហគមន៍ ១១៤៣

០៦-៣-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៣០៣/១០៨ ស្តីពីការ តែងតាំង ឯកឧត្តមចំនួន ០២ រូប ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភា ១១៤៤

១៩-០២-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០២០៣/០៧១ ស្តីពីការប្រោសព្រះរាជទាន :
ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ ឯកឧត្តម **មិន យិន**
ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ចំពោះ ឯកឧត្តម ០៣ រូប
គ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ចំពោះ លោក **និត្យ ស៊ុនថន** ១១៤៥

១៣-៣-២០០៣ - ព្រះរាជក្រឹត្យ នស/រកត/០៣០៣/០២១ស្តីពីការប្រោសព្រះរាជទានចំពោះឯកឧត្តម **តាច សេខហួរ** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ១១៤៦

១៣-៣-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៣០៣/១២២ ស្តីពីការប្រោសព្រះរាជទាន :
១-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះឧកញ៉ា **ស៊ុម ចណ្ណា**
២- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ ឧកញ៉ា **ឈន ថាវី** ១១៤៧

១៣-៣-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៣០៣/១២៣ ស្តីពីការតែងតាំង ឯកឧត្តម **ថៃ នីណុ** ជា **ឧកញ៉ា** ១១៤៨


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


១៨-៣-២០០៣ -អនុក្រឹត្យលេខ ១៧ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១១៤៩

១៩-៣-២០០៣ -អនុក្រឹត្យលេខ ១៨ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ១១៥១

១៩-៣-២០០៣ -អនុក្រឹត្យលេខ ១៩ អនក្រ.បក ស្តីពីការសម្បទានដីសង្គមកិច្ច ១១៦២

១៧-៣-២០០៣ -អនុក្រឹត្យលេខ ២៣៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១១៨១

១៨-៣-២០០៣ -អនុក្រឹត្យលេខ ២៣៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១១៨៧

១៨-៣-២០០៣ -អនុក្រឹត្យលេខ ២៤០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១១៨៨

១៨-៣-២០០៣ -អនុក្រឹត្យលេខ ២៤១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១១៩១

១៨-៣-២០០៣ -អនុក្រឹត្យលេខ ២៤២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១១៩២

## ខ

១៨-៣-២០០៣ -អនុក្រឹត្យលេខ ២៤៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១១៩៤

១៨-៣-២០០៣ -អនុក្រឹត្យលេខ ២៤៤អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១១៩៥

១៨-៣-២០០៣ -អនុក្រឹត្យលេខ ២៤៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១១៩៦

១៨-៣-២០០៣ -អនុក្រឹត្យលេខ ២៤៦អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១១៩៧

១៨-៣-២០០៣ -អនុក្រឹត្យលេខ ២៤៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១១៩៨

១៨-៣-២០០៣ -អនុក្រឹត្យលេខ ២៤៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១១៩៩

១៩-៣-២០០៣ -អនុក្រឹត្យលេខ ២៤៩ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ ១២០០

១៩-៣-២០០៣ -អនុក្រឹត្យលេខ ២៥០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១២០១

១៩-៣-២០០៣ -អនុក្រឹត្យលេខ ២៥១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១២០៣

២១-៣-២០០៣ -អនុក្រឹត្យលេខ ២៥២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២០៤

២១-៣-២០០៣ -អនុក្រឹត្យលេខ ២៥៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២០៥

២១-៣-២០០៣ -អនុក្រឹត្យលេខ ២៥៤ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ១២០៦

២១-៣-២០០៣ -អនុក្រឹត្យលេខ ២៥៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ១២០៧

### III-ការងារបណ្តាក្រសួង

#### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៧-៣-២០០៣ -ប្រកាសអន្តរក្រសួង លេខ ១៥៦ សហវ ស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទាន នៅទីស្តីការគណៈរដ្ឋមន្ត្រី ១២០៨

#### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

០៦-០២-២០០៣ -សារាចរណែនាំលេខ ០៤ សរណន.សកបយ ស្តីពីការណែនាំអនុវត្តអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ ស្តីពីការកែសំរួល ការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទា វិជ្ជា ជីវៈចំពោះមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធបៀវត្សថ្មី ១២១១

#### ៣- ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

២១-៣-២០០៣ -ប្រកាសលេខ ១២៣ ប្រក.សក.បធ ស្តីពីការដាក់អោយសាលាបច្ចេកទេស ហ្ស៊ី វ៉េ សេ ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ១២១៥

#### ៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

១៧-៣-២០០៣ - ប្រកាសលេខ ៥៨ ប្រក.វវស ស្តីពីការកំណត់និមិត្តសញ្ញាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ១២១៦

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៣/១០៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ១៩២ រស ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៣

## ត្រាស់បង្គាប់

**មាត្រា១** .- តែងតាំងឯកឧត្តមវេជ្ជបណ្ឌិត **យឹម សំអឿន** ជាទីប្រឹក្សាប្រធានរដ្ឋសភា ទទួលបន្ទុកកិច្ចការសុខាភិបាល និងអភិវឌ្ឍន៍សហគមន៍ មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស បន្ថែមលើតួនាទីបច្ចុប្បន្ន។

**មាត្រា២** .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខៈ ៩៨ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ឈាវ ឌី ធៅន

ពរល-០៣-០៣-១១២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិនា ឆ្នាំ ២០០៣

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៣/១០៨

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងឯកឧត្តម ចំនួន ០២រូបដូចខាងក្រោម ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស :

១- ឯកឧត្តមបណ្ឌិត **អន ប៊ុណ្ណាឡើន** ទទួលបន្ទុកផ្នែកនយោបាយ វិស័យពតិមាន និងសោតទស្សន៍

២- ឯកឧត្តម **តែ ស៊ុនហ៊ុង** ទទួលបន្ទុកការងារទំនាក់ទំនងអន្តរជាតិ និងវិនិយោគ

**មាត្រា ២** : ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ** លេខ: ៩៩ ច ល

ពរល-០៣-០៣-១១៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៣

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៣

**អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/០២០៣/០៧៦

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ )

**ប្រោសព្រះរាជទាន**

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១- ឯកឧត្តម **មិន ឃិន**

ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ចំពោះ :

១- ឯកឧត្តម **ជា សុខុម**
២- ឯកឧត្តម **ជា គាន**
៣- ឯកឧត្តម **ញៀម វ៉ាលី**

គ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ចំពោះ :

១- លោក **និត្យ ស៊ុនថន**

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខៈ ១០១ ច ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៣
អគ្គលេខាធិការរាជរដ្ឋាភិបាល
នៃស្រាង ស៊ាន

៣រស-០៣.០២.០៧៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៣*

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៣/១២១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

**ប្រោសព្រះរាជទាន**

**ចំពោះ**

ឯកឧត្តម **តាង សេងហួរ**

**នូវ**

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខៈ ១០៤៥ ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**

៣រល.០៣.០៣.១២៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣*

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៣/១៧២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

**ប្រោសព្រះរាជទាន**

១- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :

- ឧកញ៉ា **ស៊ឹម វណ្ណា**

២- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

- ឧកញ៉ា **ឈន ថាវី**

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ: ១០៧ ចល
ដើម្បីចម្លងចែក

៣រស-០៣.០៣-១៣០

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ៣ ឆ្នាំ២០០៣

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣*

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាងី ?ាន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៣/១២៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

**តែងតាំង**

**ឯកឧត្តម ថៃ ធីឈូ**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**
**នរោត្តម សីហនុ**

លេខ: ១០០ ច ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០៣ ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
[illegible]

*៣៩៧-០៣-០៣-១៣១*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិនា ឆ្នាំ ២០០៣*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១. ចុះថ្ងៃទី ៣០ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បកចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកាចំនួន ៥.០០០ លានរៀល ( ប្រាំពាន់លានរៀលគត់ ) ពីជំពូក ៤០ (ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ ) ជូនក្រសួងមហាផ្ទៃ" ផ្នែករដ្ឋបាលទូទៅ" សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ចំណាយទូទាត់បំណុលថ្លៃផលិតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនក្រុមហ៊ុន **ឈុន ហុង** ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១៧ ខែ មីនា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ឧសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៨ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅ នៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី លក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និង វិជ្ជាជីវៈគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្ត

ព្រះរាជក្រម លក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ

- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី២៨ ខែ កុម្ភៈ ឆ្នាំ ២០០៣

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់ការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និង សវនករកម្ពុជា ព្រមទាំងកំណត់លក្ខខណ្ឌនៃការប្រកបវិជ្ជាជីវគណនេយ្យករជំនាញ និងសវនករប្រតិស្រុត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងឱ្យវិទ្យាស្ថាននេះ :-

-ផ្តល់ជូនអង្គភាពវិជ្ជាជីវៈមួយដែលទទួលខុសត្រូវជាតំណាងនៃសមាជិករបស់ខ្លួន ព្រមទាំងលើកតម្កើងនិងការពារលក្ខន្តិកៈ និងផលប្រយោជន៍នៃវិជ្ជាជីវគណនេយ្យ

-ចូលរួមបំពេញការងារជាសមាជិក នៃក្រុមប្រឹក្សាជាតិគណនេយ្យ

-រៀបចំនិងធ្វើឱ្យមានការគោរពវិធាន និងកាតព្វកិច្ចនៃវិជ្ជាជីវៈ

-រៀបចំការបណ្តុះបណ្តាលវិជ្ជាជីវគណនេយ្យ និងសវនកម្មដល់ប្រជាពលរដ្ឋខ្មែរ ដែលជ្រើសរើសយកអាជីពទាំងពីរនេះ ។

**មាត្រា ២.-**

វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា មានអក្សរកាត់ **វ.គ.ស.ក.** ដែលមានទីតាំងនៅក្នុងរាជធានីភ្នំពេញ ។

**មាត្រា ៣.-**

**វ.គ.ស.ក.** ត្រូវស្ថិតនៅក្រោមអាណាព្យាបាល របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ស្នងការរាជរដ្ឋាភិបាលនៅអម **វ.គ.ស.ក.** ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ជំពូកទី ២

## ការគ្រប់គ្រងនិងការប្រព្រឹត្តទៅរបស់ វ.គ.ស.ក.

**មាត្រា ៤.-**

អង្គការគ្រប់គ្រងជាមូលដ្ឋានរបស់ **វ.គ.ស.ក.** មាន :-

- សន្និបាតសមាជិក
- ក្រុមប្រឹក្សាភិបាល
- គណៈកម្មាធិការសីលធម៌នៃវិជ្ជាជីវៈ
- គណៈកម្មការរៀបចំការចុះឈ្មោះ គណនេយ្យករជំនាញ និង សវនករប្រតិស្រុត
- គណៈកម្មការការងារ ការសិក្សា និង ការស្រាវជ្រាវ
- លេខាធិការដ្ឋាន ។

**វ.គ.ស.ក.** អាចបង្កើតការិយាល័យសាខានៅគ្រប់ ខេត្ត ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥.-**

ក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះមានសមាសភាពយ៉ាងច្រើនចំនួន ប្រាំបួន (៩) រូប ។

សមាជិកក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** ត្រូវបានជ្រើសរើសសម្រាប់អាណត្តិបួន (៤) ឆ្នាំ ក្នុងចំណោមសមាជិកសកម្មដោយការបោះឆ្នោតសម្ងាត់របស់សន្និបាតសមាជិកដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកវត្តមាន ។

នីតិវិធីនៃការរៀបចំ និង ការជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៦.-**

ក្នុងអំឡុងពេល ពីរ (២) ឆ្នាំ ក្រុមប្រឹក្សាភិបាលតែងតាំងជាលើកដំបូង ដូចមានចែងនៅមាត្រា ២១ នៃអន្តរប្បញ្ញត្តិរបស់អនុក្រឹត្យនេះ មានភារកិច្ចរៀបចំ :-

-បទបញ្ជាផ្ទៃក្នុងរបស់ **វ.គ.ស.ក.**

4

-ក្រមសីលធម៌នៃគណនេយ្យករជំនាញ និងសវនករប្រតិស្រុត

-ក្រមកាតព្វកិច្ចនៃវិជ្ជាជីវៈ សម្រាប់រាល់សមាជិកនៃ **វ.គ.ស.ក.**

-បទបញ្ជារដ្ឋបាល និងលក្ខខណ្ឌនៃការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាវិន័យ ដូចដែលមានចែងនៅមាត្រា ៧ នៃអនុក្រឹត្យនេះ

-បទបញ្ជាផ្ទៃក្នុងកំណត់ពីភារកិច្ច និងកាតព្វកិច្ចរបស់សមាជិក ព្រមទាំងលក្ខខណ្ឌទាំងឡាយនៃកិច្ចព្រមព្រៀងចុះហត្ថលេខាជាមួយគណនេយ្យករជំនាញ និងសវនករប្រតិស្រុតបរទេស ។ បទបញ្ជាផ្ទៃក្នុង ក៏កំណត់ផងដែរ ពីហេតុការណ៍ដែលបណ្តាលឱ្យបាត់បង់ឋានៈជាសមាជិក ។

**មាត្រា ៧.-**

ក្រុមប្រឹក្សាវិន័យមួយ ត្រូវបង្កើតឡើងនៅអម **វ.គ.ស.ក.** សម្រាប់ទទួលបន្ទុកដាក់ទោសវិន័យលើការប្រព្រឹត្តល្មើសដោយចេតនា និងមានភស្តុតាងគ្រប់គ្រាន់ខុសនឹងក្រមសីលធម៌ នៃវិជ្ជាជីវៈ ក្រមកាតព្វកិច្ចវិជ្ជាជីវៈល្មើសនឹងបទបញ្ជាផ្ទៃក្នុងរបស់ **វ.គ.ស.ក.** និងជាទូទៅ រាល់ការប្រព្រឹត្តល្មើសនឹងវិធានណាមួយនៃវិធានទាំងឡាយ ស្តីពីវិជ្ជាជីវៈរបស់គណនេយ្យករជំនាញ និងសវនករប្រតិស្រុត ។

ក្រុមប្រឹក្សាវិន័យអាចទទួលពាក្យបណ្តឹងផងដែរ អំពីរាល់អំពើល្មើសធ្ងន់ធ្ងររបស់សមាជិក **វ.គ.ស.ក.** ដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសវិជ្ជាជីវៈ ជាអាទិ៍ :-

-ការប្រព្រឹត្តអំពើទុច្ចរិតដែលបានបង្ហាញនៅចំពោះមុខតតិយជន

-អំពើពុករលួយ

-ការកែបំបាត់មូលនិធិ

-ការក្លែងបន្លំឯកសារផ្សេងៗ ក្នុងគោលបំណងបំភ័ន្តអ្នកដទៃ

-ការបំភ័ន្តក្នុងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាវិន័យមានសមត្ថកិច្ចទទួលពាក្យបណ្តឹង ដើម្បីវិនិច្ឆ័យលើរាល់ការស្នើសុំលុបចោលសេចក្តីសម្រេចរបស់គណៈកម្មការរៀបចំការចុះឈ្មោះសមាជិកស្តីពីការចុះឈ្មោះ និងការលុបឈ្មោះសមាជិកក្នុងតារាងវិជ្ជាជីវគណនេយ្យករជំនាញ និងតារាងវិជ្ជាជីវសវនករប្រតិស្រុត ។

**មាត្រា ៨.-**

ដើម្បីធានាឱ្យមានតម្លាភាព ភាពត្រឹមត្រូវ និងភាពស្មោះត្រង់ រាល់របាយការណ៍គណនេយ្យរបស់ **វ.គ.ស.ក.** ត្រូវមានការផ្ទៀងផ្ទាត់ និងវិញ្ញាបនកម្មដោយសិក្សាភិរក្សពេញសិទ្ធិមួយ (១) រូប និងអ្នក

ជំនួសមួយ (១) រូប ដែលនឹងត្រូវជ្រើសតាំងក្នុងចំណោមសមាជិក ដែលបានចុះឈ្មោះក្នុងតារាងវិជ្ជាជីវៈទាំងពីរ ដូចដែលបានចែងនៅក្នុងមាត្រា ៩ នៃអនុក្រឹត្យនេះ ។

សិក្សាភិរក្សជំនួសមានតួនាទីជាអ្នកជំនួស សិក្សាភិរក្សពេញសិទ្ធិក្នុងករណីសិក្សាភិរក្សពេញសិទ្ធិ មានធុរៈ ឬ ទទួលមរណភាព ។ អាណត្តិរបស់សិក្សាភិរក្សមានរយៈពេលមួយ (១) ឆ្នាំ ដែលអាចបន្តទៀត បាននៅរាល់ពេលមហាសន្និបាតប្រចាំឆ្នាំនីមួយៗ អនុម័តយល់ព្រម ។

មុខងារជាសិក្សាភិរក្សមានវិសមិតភាព ជាមួយនឹងមុខងារជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ **វ.គ.ស.ក.** ។

សិក្សាភិរក្សពេញសិទ្ធត្រូវបំពេញបេសកកម្មរបស់ខ្លួន និងធ្វើរបាយការណ៍ចែកជូនសមាជិក **វ.គ.ស.ក.** ទាំងអស់ ឱ្យបានយ៉ាងតិចដប់ប្រាំ (១៥) ថ្ងៃ មុនថ្ងៃប្រជុំសន្និបាតប្រចាំឆ្នាំ ។

សិក្សាភិរក្សត្រូវឡើងអានរបាយការណ៍របស់ខ្លួនជូនសន្និបាត និងត្រូវបញ្ជាក់ពីភាពត្រឹមត្រូវនៃ ធនធានហិរញ្ញវត្ថុរបស់ **វ.គ.ស.ក.** សម្រាប់ការិយបរិច្ឆេទដែលបានកន្លងទៅ ។

សិក្សាភិរក្សត្រូវបានឱ្យរួចផុតពីការទទួលខុសត្រូវ លុះត្រាណាតែរបាយការណ៍គណនេយ្យ ដែល មានការផ្ទៀងផ្ទាត់ និងវិញ្ញាបនកម្មរបស់ខ្លួននោះបានទទួលការយល់ព្រមពីសន្និបាតប្រចាំឆ្នាំរបស់ **វ.គ.ស.ក.** ។

**មាត្រា ៩.-**

គណៈកម្មការរៀបចំការចុះឈ្មោះគណនេយ្យករជំនាញ និងសវនករប្រតិស្រុត ដូចមានចែងក្នុង មាត្រា ៤នៃអនុក្រឹត្យនេះមានសិទ្ធិក្នុងការរៀបចំតារាងវិជ្ជាជីវៈគណនេយ្យករជំនាញ និងតារាងវិជ្ជាជីវៈ សវនករប្រតិស្រុត សម្រាប់បុគ្គលទាំងឡាយដែលប្រកបវិជ្ជាជីវៈជាឯកត្តជន ឬជាក្រុមហ៊ុនមានឋានៈជា គណនេយ្យករជំនាញ ឬសវនករប្រតិស្រុតលើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះ ។ តារាងទាំងពីរនេះ គឺជាឯកសារផ្លូវការរបស់ **វ.គ.ស.ក.** ដែលត្រូវបានផ្តល់ជូន ដោយឥតគិតថ្លៃដល់រាល់សមាជិករបស់ **វ.គ.ស.ក.** និង ដល់ស្ថាប័នរដ្ឋនានា ។

តារាងនីមួយៗ ត្រូវបែងចែកជា បី (៣) ផ្នែក :-

- ផ្នែកគណនេយ្យករជំនាញ និងសវនករប្រតិស្រុត សមាជិករូបវន្តនៃ **វ.គ.ស.ក.**
- ផ្នែកក្រុមហ៊ុនគណនេយ្យករជំនាញ និងសវនករប្រតិស្រុត សមាជិកនៃ **វ.គ.ស.ក.**
- ផ្នែកបុគ្គលនិងនីតិបុគ្គលបរទេសដែលត្រូវបានអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈជាគណនេយ្យករ ជំនាញ និងសវនករប្រតិស្រុតក្រោមកិច្ចព្រមព្រៀងចុះហត្ថលេខាជាមួយ **វ.គ.ស.ក.** ។

# ជំពូកទី ៣

## អំពីសមាជិក វ.គ.ស.ក.

**មាត្រា ១០.-**

ប្រភេទផ្សេងៗនៃសមាជិក **វ.គ.ស.ក.** រួមមាន :-

- សមាជិកចូលរួម
- សមាជិកសកម្ម
- សមាជិកបម្រុង ។

**សមាជិកចូលរួម**គឺរាល់បុគ្គលដែលមានលក្ខណៈសម្បត្តិកម្រិតសកលវិទ្យាល័យផ្នែកគណនេយ្យ ផ្នែកកិច្ចការជំនួញ ឬផ្នែកហិរញ្ញវត្ថុ ក្នុងកម្រិតបទដ្ឋានដែលបានទទួលស្គាល់ និងអាចទទួលយកបានដោយគណៈកម្មការរៀបចំការចុះឈ្មោះគណនេយ្យករជំនាញ និងសវនករប្រតិស្រុត ។

**សមាជិកសកម្ម** គឺគ្រប់សមាជិកចូលរួម ដែលបំពេញលក្ខខណ្ឌដែលបានតម្រូវដើម្បីចុះឈ្មោះក្នុងតារាងវិជ្ជាជីវៈដែលមានចែងក្នុងមាត្រា ៩ នៃអនុក្រឹត្យនេះ ដោយផ្អែកលើសមត្ថកិច្ច សញ្ញាបត្រ និងសម្បទាក្នុងការប្រកបវិជ្ជាជីវៈនៃសមាជិកនោះ ។

បទប្បញ្ញត្តិនៃលក្ខខណ្ឌទាំងឡាយ ដើម្បីផ្តល់ឋានៈជាសមាជិកសកម្ម មិនអាចជំទាស់ចំពោះការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល ក្នុងការទទួលយករាល់បុគ្គលឱ្យចូលក្នុងឋានៈជាសមាជិកសកម្ម ដែលក្រុមប្រឹក្សាភិបាល បានវិនិច្ឆ័យថា បុគ្គលនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ឋានៈនេះ ។

**សមាជិកបម្រុង** គឺរាល់បុគ្គលដែលមានចំណេះដឹង ផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ និងដែលបានវិនិច្ឆ័យថាគ្រប់គ្រាន់ដោយគណៈកម្មការរៀបចំការចុះឈ្មោះសម្រាប់បន្តកម្មសិក្សាវិជ្ជាជីវៈ ឬបំពេញការសិក្សាដើម្បីក្លាយខ្លួនជាគណនេយ្យករជំនាញ និងឬជា សវនករប្រតិស្រុត ។

សមាជិកបម្រុងមិនអាចប្រកបវិជ្ជាជីវៈជាគណនេយ្យករជំនាញ និងជាសវនករប្រតិស្រុតបានទេ ។ សមាជិកបម្រុង ជាអ្នកមានសិទ្ធិបោះឆ្នោត តែមិនអាចឈរឈ្មោះឱ្យគេបោះឆ្នោតបានឡើយ ។

**មាត្រា ១១.-**

មុខងារជាសមាជិករបស់ **វ.គ.ស.ក.** ដែលកំពុងប្រកបវិជ្ជាជីវៈ ជាគណនេយ្យករជំនាញ ឬសវនករប្រតិស្រុត មានវិសមិតភាពជាមួយនឹងរាល់មុខងារ ឬរាល់សកម្មភាពដែលធ្វើឱ្យប៉ះពាល់ដល់ ឯករាជ្យភាពរបស់ គណនេយ្យករជំនាញ ឬសវនករប្រតិស្រុត។

សមាជិករបស់ **វ.គ.ស.ក.** ត្រូវបានហាមឃាត់ មិនឱ្យមានមុខរបរទទួលប្រាក់បៀវត្ស អ្វីផ្សេងទៀតក្រៅពីមុខងារមានប្រាក់បៀវត្សនោះ ត្រូវបានបំពេញនៅខុទ្ទកាល័យរបស់សមាជិក**វ.គ.ស.ក.**ម្នាក់ទៀត ឬ នៅក្នុងក្រុមហ៊ុនសវនកម្ម និង/ឬគណនេយ្យកជំនាញ ដែលថ្នាក់ដឹកនាំក្រុមហ៊ុននោះជាសមាជិករបស់ **វ.គ.ស.ក.**។

សមាជិករបស់ **វ.គ.ស.ក.** ទាំងនោះអាចទទួលបេសកកម្មកោសល្យវិច័យ ដែលត្រូវបានប្រគល់ឱ្យដោយសេចក្ដីសម្រេចរបស់តុលាការនិង/ឬស្ថាប័នរដ្ឋ ដើម្បីបំពេញមុខងារជាអាជ្ញាកណ្ដាល និងការងារជាសាស្ត្រាចារ្យសកលវិទ្យាល័យ ។

## ជំពូកទី ៤
## វិជ្ជាជីវៈ
## គណនេយ្យករជំនាញ និង សវនករប្រតិស្រុត

### ផ្នែកទី ១
### អំពីវិជ្ជាជីវៈគណនេយ្យករជំនាញ

**មាត្រា ១២.-**

គណនេយ្យករជំនាញ គឺជាអ្នកប្រកបវិជ្ជាជីវសេរី ដែលមិនជាប់ពាក់ព័ន្ធនឹងកិច្ចសន្យាការងារជាមួយអង្គភាពដែលខ្លួនអនុវត្តភារកិច្ចក្នុងការ :-

-កាន់បញ្ជីគណនេយ្យ

-ប្រមូលផ្ដុំបញ្ជីគណនេយ្យ

-បើកបញ្ជីគណនេយ្យ

-បិទបញ្ជីគណនេយ្យ

-ត្រួតពិនិត្យបញ្ជីគណនេយ្យ

-ផ្ទៀងផ្ទាត់បញ្ជីគណនេយ្យ

ſk

-ធ្វើនិយតកម្មបញ្ជីគណនេយ្យ

-វាយតម្លៃនិងបញ្ចូលគ្នានូវបញ្ជីគណនេយ្យសហគ្រាសនិងអង្គភាពនានា

-រៀបចំនូវរាល់វិធានគណនេយ្យ និងវិភាគតាមនីតិវិធីបច្ចេកទេសគណនេយ្យ នូវរបាយការណ៍ហិរញ្ញវត្ថុ និងស្ថានភាពប្រតិបត្តិការរបស់ក្រុមហ៊ុនស្របទៅតាមទិដ្ឋភាពទាំងឡាយ ក្នុងវិស័យសេដ្ឋកិច្ច គតិយុត្ត និងហិរញ្ញវត្ថុ

-រាយការណ៍ជាលាយលក្ខណ៍អក្សរពីការងាររបស់ខ្លួន ដោយមានចែងនូវសេចក្តីសង្កេត សេចក្តីសន្និដ្ឋាន និងសំណូមពរ ។

គណនេយ្យករជំនាញត្រូវមាននីតិសម្បទាដើម្បីបញ្ជាក់ពីប្រក្រតីភាព និងភាពស្មោះត្រង់នៃរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ។

**មាត្រា ១៣.-**

គ្មានបុគ្គលណាអាចប្រកបវិជ្ជាជីវៈជាគណនេយ្យករជំនាញបានទេ ប្រសិនបើបុគ្គលនោះមិនបានចុះឈ្មោះ ក្នុងតារាងវិជ្ជាជីវគណនេយ្យករជំនាញរបស់ **វ.គ.ស.ក.**ដូចមានចែងក្នុងមាត្រា ៩នៃអនុក្រឹត្យនេះ។ ដោយឡែកពីការអនុវត្តលក្ខខណ្ឌទាំងឡាយ នៃបទបញ្ជាផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការចុះឈ្មោះជនបរទេស មានវិជ្ជាជីវៈជាគណនេយ្យករជំនាញ ការចុះឈ្មោះក្នុងតារាងវិជ្ជាជីវៈរបស់ **វ.គ.ស.ក.**ក្នុងឋានៈជាគណនេយ្យករជំនាញត្រូវមានលក្ខណវិនិច្ឆ័យដូចតទៅ :-

១. ត្រូវមានសញ្ជាតិជាខ្មែរ ។

២. ត្រូវមានអាយុម្ភៃប្រាំ (២៥) ឆ្នាំ យ៉ាងតិច គិតដល់ថ្ងៃទទួលពាក្យសុំចុះឈ្មោះចូលជាសមាជិក **វ.គ.ស.ក.** ។

៣. ត្រូវមានសិទ្ធិពលរដ្ឋគ្រប់គ្រាន់ ។

៤. មិនដែលរងការផ្តន្ទាទោស ពីបទឧក្រិដ្ឋ ឬបទល្មើសមជ្ឈិម ដោយមានលិខិតថ្កោលទោសត្រឹមត្រូវ ។

៥. ត្រូវមានសញ្ញាបត្រគណនេយ្យករជំនាញ ឬសញ្ញាបត្រសមមូលដែលទទួលស្គាល់ដោយគណៈកម្មការរៀបចំការចុះឈ្មោះ គណនេយ្យករជំនាញ និងសវនករប្រតិស្រុត។

Ա

**មាត្រា ១៤.-**

រូបវន្តបុគ្គលនិង/ឬនីតិបុគ្គលអាចចុះឈ្មោះក្នុងតារាងវិជ្ជាជីវៈនៃក្រុមហ៊ុនគណនេយ្យករជំនាញបាន លុះត្រាតែបានបំពេញលក្ខខណ្ឌនៃការចុះឈ្មោះ ដែលបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **វ.គ.ស.ក.** ។ លក្ខន្តិកៈក្រុមហ៊ុន ត្រូវអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ **វ.គ.ស.ក.** ។

**មាត្រា ១៥.-**

គណនេយ្យករជំនាញដែលមានឈ្មោះក្នុងតារាងវិជ្ជាជីវៈរបស់ **វ.គ.ស.ក.** ត្រូវទទួលខុសត្រូវក្នុងកិច្ចការរបស់ខ្លួន ។ គណនេយ្យករជំនាញត្រូវគោរពបទប្បញ្ញត្តិច្បាប់ និងបទបញ្ជាទាំងឡាយជាធរមាន និងក្រមសីលធម៌ ស្តីពីវិជ្ជាជីវៈ ព្រមទាំងបទបញ្ជាផ្ទៃក្នុងរបស់ **វ.គ.ស.ក.** ។

គណនេយ្យករជំនាញ ត្រូវមានកិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈ ដើម្បីធានាលើរាល់ការទទួលខុសត្រូវដែលអាចកើតឡើងពីការងារ ឬពីសកម្មភាពរបស់ខ្លួនជាមួយតតិយជន ។

ការទទួលខុសត្រូវផ្ទាល់របស់ក្រុមហ៊ុនគណនេយ្យករជំនាញ ដែលបានចុះឈ្មោះក្នុងតារាងវិជ្ជាជីវៈរបស់ **វ.គ.ស.ក.** មិនអាចគ្របដណ្តប់ការទទួលខុសត្រូវរបស់សមាជិកម្នាក់ៗនៃ **វ.គ.ស.ក.** បានឡើយក្នុងការតំណាងឱ្យក្រុមហ៊ុនគណនេយ្យករជំនាញ ដែលខ្លួនមានភាគកម្មតាមរយៈការងារ ដែលបានបំពេញក្នុងនាមក្រុមហ៊ុន និងបានចុះហត្ថលេខាក្នុងនាមខ្លួនផ្ទាល់ និងក្នុងនាមក្រុមហ៊ុន ។

**មាត្រា ១៦.-**

សមាជិកគណនេយ្យករជំនាញរបស់ **វ.គ.ស.ក.** មានភារកិច្ចទទួលយកគណនេយ្យករជំនាញបម្រុង និងរ៉ាប់រងធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈដល់អ្នកទាំងនោះ ក្នុងលក្ខខណ្ឌដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **វ.គ.ស.ក.** ។

## ផ្នែកទី ២
## អំពីវិជ្ជាជីវសវនករប្រតិស្រុត

**មាត្រា ១៧.-**

សវនករប្រតិស្រុតជាអ្នកដែលប្រកបវិជ្ជាជីវៈក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់ខ្លួនផ្ទាល់ដើម្បីបញ្ជាក់អំពីភាពទៀងទាត់ និងភាពស្មោះត្រង់នៃរបាយការណ៍ហិរញ្ញវត្ថុរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលសវនករប្រតិស្រុតនោះ អនុវត្តការងារសវនកម្ម តាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន ឬតាមកិច្ចព្រមព្រៀង ។

៤៧

**មាត្រា ១៨.-**

គ្មានបុគ្គលណាអាចប្រកបវិជ្ជាជីវៈជាសវនករប្រតិស្រុតបានទេ ប្រសិនបើបុគ្គលនោះមិនបានចុះឈ្មោះក្នុងតារាងវិជ្ជាជីវៈសវនករប្រតិស្រុតរបស់ **វ.គ.ស.ក.** ដូចដែលមានចែងក្នុងមាត្រា៩នៃអនុក្រឹត្យនេះ ។

ការចុះឈ្មោះក្នុងតារាងវិជ្ជាជីវៈរបស់ **វ.គ.ស.ក.** ក្នុងឋានៈជាសវនករប្រតិស្រុត ត្រូវគោរពតាមលក្ខណវិនិច្ឆ័យ ដូចគ្នានឹងលក្ខណវិនិច្ឆ័យរបស់គណនេយ្យករជំនាញ ដែលមានចែងក្នុងមាត្រា ១៣នៃអនុក្រឹត្យនេះ ។

**មាត្រា ១៩.-**

សវនករប្រតិស្រុតជាសមាជិករបស់ **វ.គ.ស.ក.** អាចបង្កើតក្រុមហ៊ុនពាណិជ្ជកម្មបានស្របទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ **វ.គ.ស.ក.** និងច្បាប់ពាក់ព័ន្ធជាធរមាន។

**មាត្រា ២០.-**

គណៈកម្មការត្រួតពិនិត្យមួយត្រូវបង្កើតឡើងនៅអម **វ.គ.ស.ក.** ដើម្បីធ្វើអធិការកិច្ចលើការអនុវត្តរបស់សវនករប្រតិស្រុត ក្នុងវិស័យឯករាជ្យការងារ និងការយកចិត្តទុកដាក់ក្នុងវិជ្ជាជីវៈ ។ សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការត្រួតពិនិត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**មាត្រា ២១.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញប្រកាសតែងតាំង ប្រធានមួយ (១) រូប អនុប្រធាន មួយ (១) រូប ហិរញ្ញិក មួយ (១) រូប និងសមាជិក ពីរ (២) រូបទៀត សម្រាប់ដំណើរការដំបូងរបស់ក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** ។

ឃ

## ទោសប្បញ្ញត្តិ

**មាត្រា ២២.-**

ការប្រកបវិជ្ជាជីវៈជាគណនេយ្យករជំនាញ និង/ឬ សវនករប្រតិស្រុត ដោយល្មើសនឹងមាត្រា ៩ ១៣ និងមាត្រា ១៨ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ២៣.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល :-***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៤
- ឯកសារ/កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១៩ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## សម្បទានដីសង្គមកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៣

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់នីតិវិធី លក្ខណវិនិច្ឆ័យ និងយន្តការសម្រាប់ធ្វើការផ្តល់សម្បទានដីសង្គមកិច្ច ដើម្បីសង់លំនៅឋាន ឬ/និងដើម្បីធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។

**មាត្រា ២.-**

ពាក្យទាំងឡាយខាងក្រោមនេះ មានន័យដូចតទៅ ៖

- សម្បទានដីសង្គមកិច្ច គឺជាយន្តការផ្ទេរដីឯកជនរបស់រដ្ឋតាមផ្លូវច្បាប់សម្រាប់គោលបំណងសង្គមកិច្ច ដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅឋាន ឬ/និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ
- ដីសម្បទានសង្គមកិច្ច គឺជាដីដែលជាកម្មវត្ថុនៃសម្បទានដីសង្គមកិច្ច
- ការធ្វើកសិកម្មជាលក្ខណៈគ្រួសារ សំដៅសកម្មភាពដាំដុះណាំ ឬចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ដើម្បីបំពេញសេចក្តីត្រូវការជាមូលដ្ឋាន ។

**មាត្រា ៣.-**

ដីសម្បទានសង្គមកិច្ច អាចត្រូវផ្តល់ឱ្យសម្រាប់គោលដៅសង្គមកិច្ច ដោយអនុលោមតាមគោលដៅណាមួយ ឬគោលដៅច្រើន ដូចមានខាងក្រោមនេះ ៖

១- ផ្តល់ដី ដល់គ្រួសារក្រីក្រដែលគ្មានទីលំនៅសម្រាប់សង់លំនៅឋាន ។

ណ

២- ផ្តល់ដី ដល់គ្រួសារក្រីក្រសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។

៣- ផ្តល់ដី ដល់គ្រួសារដែលត្រូវផ្លាស់ប្តូរទីលំនៅបណ្តាលមក ពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈសម្រាប់ការតាំងលំនៅឋានជាថ្មី ។

៤- ផ្តល់ដី ដល់គ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ ។

៥- ផ្តល់ដី ដល់គ្រួសារមាតុភូមិនិវត្តន៍ ។

៦- ផ្តល់ដី ដល់យោធិនរំសាយ និងគ្រួសារយុទ្ធជនពលីពិការ ។

៧- ជួយសម្រួល ដល់ការអភិវឌ្ឍសេដ្ឋកិច្ច ។

៨- ជួយសម្រួល ដល់សម្បទានដីសេដ្ឋកិច្ច ដោយផ្តល់ដីឡូតិ៍ដល់កម្មករចំការធំៗសម្រាប់សង់លំនៅឋាន ឬសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។

៩- អភិវឌ្ឍតំបន់ដែលពុំទាន់ត្រូវបានអភិវឌ្ឍសមស្រប ។

**មាត្រា ៤ .-**

កម្មវិធីសម្បទានដីសង្គមកិច្ច មាន ៖

- កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន
- កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

## ជំពូកទី ២
## កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន

**មាត្រា ៥ .-**

ក្រុមប្រឹក្សាឃុំសង្កាត់ ជាអ្នកផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របតាមលក្ខខណ្ឌចាំបាច់ នៃផែនការសម្បទានដីសង្គមកិច្ច ដូចមានចែងក្នុងជំពូកទី ៤នៃអនុក្រឹត្យនេះ ។

ប្រជាពលរដ្ឋម្នាក់ ឬច្រើននាក់ ឬអង្គការដែលធ្វើការជាមួយប្រជាពលរដ្ឋ ឬតំណាងប្រជាពលរដ្ឋនៃឃុំសង្កាត់នោះ ក៏អាចផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានបានដែរ ប៉ុន្តែត្រូវធ្វើតាមរយៈក្រុមប្រឹក្សាឃុំ សង្កាត់នៃឃុំ សង្កាត់ដែលដីសម្បទានសង្គមកិច្ចនោះឋិតនៅ ដោយរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របតាមលក្ខខណ្ឌចាំបាច់ នៃផែនការសម្បទានដីសង្គមកិច្ច ដូចមានចែងក្នុងជំពូកទី ៤នៃអនុក្រឹត្យនេះ ។

ℒ

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវពិនិត្យផែនការសម្បទានដីសង្គមកិច្ចប្រចាំឆ្នាំ ដោយអនុលោមតាមនីតិវិធីនៃការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ ដូចមានចែងក្នុងជំពូកទី ៦នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ៦ .-**

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ជូនផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន តាមរយៈក្រុមការងារថ្នាក់ស្រុក ខណ្ឌ ទៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ដើម្បីសុំការសម្រេចយល់ព្រម ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង អាចផ្តល់ការសម្រេចយល់ព្រម លើផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ប្រសិនបើ ផែនការសម្បទានដីសង្គមកិច្ចនោះ ត្រឹមត្រូវតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ដោយអនុក្រឹត្យនេះ និងប្រសិនបើពិនិត្យឃើញថា ដីនោះជាដីឯកជនរបស់រដ្ឋដែលនៅទំនេរ ហើយសមស្របសម្រាប់ផែនការសម្បទានដីសង្គមកិច្ច ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ត្រូវជូនដំណឹង ដល់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អំពីផែនការនីមួយៗ ដែលគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង បានផ្តល់ការសម្រេចយល់ព្រម ។ គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចពិនិត្យកែសម្រួលផែនការ ឬលុបចោលសេចក្តីសម្រេចយល់ព្រម របស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ គិតពីថ្ងៃបានទទួលផែនការសម្បទានដីសង្គមកិច្ចនេះ ប្រសិនបើ ៖

ក- ផែនការសម្បទានដីសង្គមកិច្ចនោះ មិនស្របនឹងអាទិភាពនៃការប្រើប្រាស់ដីថ្នាក់ជាតិ មានកំហុសបច្ចេកទេស ឬរំលោភបទប្បញ្ញត្តិទាំងឡាយនៃអនុក្រឹត្យនេះ ឬច្បាប់ផ្សេងទៀត ។

ខ- ផែនការដែលបានយល់ព្រម មិនស្របនឹងលក្ខខណ្ឌចាំបាច់ នៃកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

បន្ទាប់ពីបានការយល់ព្រម ក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានជំនួយបច្ចេកទេស ពីក្រុមការងារថ្នាក់ស្រុក ខណ្ឌ ជាអ្នកអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ។ ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដែលបានទទួលការសម្រេចយល់ព្រមរួចហើយ ត្រូវបើកចំហជាសាធារណៈនៅសាលាឃុំ សង្កាត់ពាក់ព័ន្ធ នៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង និងនៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ក្នុងអំឡុងពេលម៉ោងធ្វើការ ។

# ជំពូកទី ៣
# កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

## មាត្រា ៧.-

កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចត្រូវបានផ្តួចផ្តើមឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធមួយ ឬច្រើន ក្នុងស្ថានភាពដែលកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន មិនអាចធ្វើបាន ពិសេសក្នុងស្ថានភាពណាមួយ ដូចខាងក្រោម ៖

- កន្លែងដែលមានកម្មវិធីអភិវឌ្ឍដីនៅតំបន់ដាច់ស្រយាល ដែលពុំទាន់មានប្រជាជនមូលដ្ឋានគ្រប់គ្រាន់ ដើម្បីអភិវឌ្ឍដីនោះ
- កន្លែងដែលមានកម្មវិធីតាំងទីលំនៅថ្មី សម្រាប់គ្រួសារច្រើន ដូចជាករណីដំណោះស្រាយសំណង់បណ្តោះអាសន្ននៅតាមទីប្រជុំជន ឬគ្រួសារដែលត្រូវផ្លាស់ប្តូរទីកន្លែង
- កន្លែងដែលកម្មវិធីសម្បទានដីសង្គមកិច្ច អាចផ្សារភ្ជាប់ទៅនឹងសម្បទានដីសេដ្ឋកិច្ច ដើម្បីអភិវឌ្ឍកសិឧស្សាហកម្ម
- កន្លែងដែលមានកម្មវិធីអភិវឌ្ឍថ្មី ឬមានកម្មវិធីអភិវឌ្ឍស្រាប់ ដែលត្រូវសម្របសម្រួលដោយថ្នាក់ជាតិ ដូចជា កម្មវិធីដែលគាំទ្រដោយអ្នកផ្តល់ជំនួយ ឬអ្នកវិនិយោគ
- កន្លែងដែលតម្រូវឱ្យមានសម្បទានដីសង្គមកិច្ច ដែលថ្នាក់មូលដ្ឋានមិនអាចធ្វើកម្មវិធីបាន ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវដាក់ផែនការសម្បទានដីសង្គមកិច្ច ដែលបានបំពេញលក្ខខណ្ឌចាំបាច់នៃផែនការសម្បទានដីសង្គមកិច្ច ដូចមានចែងក្នុងជំពូកទី ៤នៃអនុក្រឹត្យនេះ ជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ ។

នៅក្នុងការផ្តួចផ្តើម ផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវមានការចូលរួមយោបល់ពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុងដែលពាក់ព័ន្ធ ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ ។

## មាត្រា ៨.-

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចផ្តល់ការយល់ព្រមលើផែនការ ដែលបានស្នើឡើង ឬអាចកែសម្រួលផែនការនេះ ដោយពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ពន្ធ័ ។

កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដែលបានទទួលការសម្រេចយល់ព្រមរួចហើយ ត្រូវអនុវត្ត

ដោយក្រសួង ស្ថាប័ន ឬម្ចាស់សំណើតាមការកំណត់ នៅក្នុងផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដោយមានការសម្របសម្រួលជាមួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ក្រុមប្រឹក្សាឃុំសង្កាត់ និងប្រជាពលរដ្ឋនៅក្នុងតំបន់ពាក់ព័ន្ធ លើកលែងតែ កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ចែងផ្សេងពីនេះ។ ផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដែលបានទទួលការសម្រេចយល់ព្រមរួចហើយ ត្រូវបើកចំហជាសាធារណៈនៅសាលាឃុំ សង្កាត់ពាក់ព័ន្ធ នៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង និងនៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ក្នុងអំឡុងពេលម៉ោងធ្វើការ ។

## ជំពូកទី ៤
## លក្ខខណ្ឌចាំបាច់ដើម្បីធ្វើផែនការសម្បទានដីសង្គមកិច្ច

**មាត្រា ៩ .-**

លក្ខខណ្ឌចាំបាច់ដើម្បីធ្វើផែនការសម្បទានដីសង្គមកិច្ច រួមមាន ៖

ក- ការពិពណ៌នាអំពីដី និងផែនការប្រើប្រាស់ដី ដែលត្រូវបំពេញតាមនីតិវិធី នៃការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ ដូចមានចែងក្នុងជំពូកទី ៦នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

ខ- ព័ត៌មានអំពីអត្តសញ្ញាណកម្មដី កម្មសិទ្ធិដី និងការបញ្ជាក់អំពីដីដែលនៅទំនេរ ដែលអាចប្រើប្រាស់បានសម្រាប់សម្បទានដីសង្គមកិច្ច ឬសមស្របសម្រាប់ប្រើប្រាស់ក្នុងផែនការសម្បទានដីសង្គមកិច្ច ។

គ- ព័ត៌មានលំអិតអំពីការជ្រើសរើសមុខសញ្ញាអ្នកទទួលដី រួមមាន ៖

- ភាពអនុគ្រោះនានាសម្រាប់ក្រុមជនងាយរងគ្រោះ ដូចមានចែងក្នុងមាត្រា ១១នៃអនុក្រឹត្យនេះ
- មធ្យោបាយដែលបានប្រើសម្រាប់ធ្វើការត្រួតពិនិត្យឡើងវិញ អំពីការបំពេញលក្ខណៈវិនិច្ឆ័យនៃភាពអាចជ្រើសរើសបាន និងភាពអនុគ្រោះរបស់មុខសញ្ញាអ្នកទទួលដី ។

ឃ-ផែនការលំអិតសម្រាប់ការបែងចែកដី ដល់មុខសញ្ញាអ្នកទទួលដី រួមទាំងលក្ខខណ្ឌពិសេសនានានៃការកាន់កាប់ និងប្រើប្រាស់ដី ។

ង- ព័ត៌មានលំអិតអំពីដំណើរការដាក់ពាក្យសុំ រួមមាន ទីកន្លែងដាក់ពាក្យ អ្នកទទួលខុសត្រូវក្នុងការផ្សព្វផ្សាយ អំពីដំណើរការដាក់ពាក្យ និងអ្នកទទួលខុសត្រូវ ក្នុងការបិទផ្សាយឈ្មោះអ្នកដាក់ពាក្យសុំ កន្លែងបិទផ្សាយសេចក្តីជូនដំណឹង ព្រមទាំងព័ត៌មានលំអិតផ្នែក

រដ្ឋបាលផ្សេងៗទៀត ។

ច- ការវាយតម្លៃអំពីលទ្ធភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីអនុវត្តផែនការនេះ ដែលរួមមាន ផ្លូវថ្នល់ ទឹក អគ្គិសនី សាលារៀន ទីផ្សារ មណ្ឌលសុខភាព ព្រមទាំងឧបករណ៍សម្ភារៈសម្រាប់អភិវឌ្ឍដី សេវាផ្សេងទៀត ព័ត៌មានអំពីរបៀប និងពេលវេលាដែលត្រូវរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផ្តល់សេវាសាធារណៈទាំងនោះ ។

ឆ- ការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាននៃកម្មវិធី និងការពិពណ៌នាអំពីវិធានការសមស្រប ។

ជ- តម្រូវការផ្សេងទៀត ត្រូវកំណត់ដោយគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

**មាត្រា ១០.-**

អ្នកសុំដីសម្បទានសង្គមកិច្ច ត្រូវមានលក្ខណសម្បត្តិដូចតទៅ ៖

ក- មានសញ្ជាតិខ្មែរ និងមានសមត្ថភាពតាមផ្លូវច្បាប់ដើម្បីធ្វើជាម្ចាស់ដី ។

ខ- ជាមេគ្រួសារនៃគ្រួសារដែលមានសមាជិកពីរនាក់ ឬច្រើននាក់ដែលជាប់សាច់សាលោហិតជាមួយគ្នា ឬមានចំណងអាពាហ៍ពិពាហ៍ និងរស់នៅជាមួយគ្នាក្នុងលំនៅឋានតែមួយ ។

គ- បំពេញលក្ខណវិនិច្ឆ័យខាងហិរញ្ញវត្ថុ ដែលកំណត់ដោយប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល និងយុវនីតិសម្បទា ដោយផ្អែកលើយោបល់របស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។ គោលការណ៍ណែនាំអំពីការវាយតម្លៃប្រាក់ចំណូល ត្រូវពិចារណាដោយផ្អែកលើទំហំគ្រួសារ និងលក្ខខណ្ឌអាយុ និងសុខភាពនៃសមាជិកគ្រួសារ ។ គោលការណ៍ណែនាំនេះ អាចប្រែប្រួលទៅតាមតំបន់ ទៅតាមពេលវេលា ស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច និងជីវភាពរស់នៅ ។

ឃ-មិនមែនជាកម្មសិទ្ធិករ ឬភោគីនៃដីផ្សេងទៀតដែលមានទំហំស្មើ ឬលើសពីការកំណត់ទំហំដីសម្បទានសង្គមកិច្ច ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ១៧នៃអនុក្រឹត្យនេះ ។

ង-បានត្រៀមខ្លួនជាស្រេច មានឆន្ទៈ និងមានលទ្ធភាពចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ស្របតាមផែនការសម្បទានដីសង្គមកិច្ច ដែលបានយល់ព្រម ។

គ្មានជនណាម្នាក់ អាចបដិសេធសិទ្ធិចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច របស់មេគ្រួសារជាស្ត្រី ជាជនបាត់បង់សមត្ថភាព ជាអតីតយុទ្ធជនដែលបាត់បង់សមត្ថភាព ជាយោធិនរំសាយបានឡើយ ។

4L

**មាត្រា ១១ .-**

ក្នុងករណី អ្នកសុំដីមានចំនួនច្រើនជាងចំនួនដីសម្បទានសង្គមកិច្ច ផែនការសម្បទានដីសង្គមកិច្ច អាចបញ្ចូលលក្ខណវិនិច្ឆ័យសមហេតុផលសម្រាប់ផ្តល់ភាពអនុគ្រោះក្នុងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ឬសម្រាប់ការបែងចែកដីសម្បទានសង្គមកិច្ច ដោយផ្អែកលើ ៖

- គ្រួសារធំ ដែលមានសមាជិកចាប់ពីប្រាំមួយ (៦) នាក់ឡើងទៅ
- រយៈពេលដែលគ្រួសារបានរស់នៅក្នុងតំបន់ដីសម្បទានសង្គមកិច្ចនោះ
- មេគ្រួសារជាស្ត្រី ជាជនដែលបាត់បង់សមត្ថភាព ជាអតីតយុទ្ធជនដែលបាត់បង់សមត្ថភាព ជាយោធិនរំសាយ ។

**មាត្រា ១២ .-**

សេចក្តីជូនដំណឹង នៃការដាក់ពាក្យសុំដីសម្បទានសង្គមកិច្ច ត្រូវធ្វើជាចំហ និងត្រូវផ្សព្វផ្សាយ នៅទីសាធារណៈមួយ ឬច្រើនកន្លែងក្នុងតំបន់ដីសម្បទាននោះ ក្នុងរយៈពេលយ៉ាងតិចសាមសិប (៣០) ថ្ងៃ មុនកាលបរិច្ឆេទនៃការទទួលពាក្យសុំ។

ប្រជាពលរដ្ឋដែលរស់នៅ ក្នុងតំបន់ដីសម្បទានសង្គមកិច្ច អាចដាក់ពាក្យសុំដីសម្បទានសង្គមកិច្ច នៅសាលាឃុំ សង្កាត់ដែលបានកំណត់ក្នុងសេចក្តីជូនដំណឹងនោះ ដោយត្រូវបំពេញតាមគំរូពាក្យសុំ ។

គំរូពាក្យសុំ ត្រូវកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

អ្នកសុំដីសម្បទានសង្គមកិច្ច ត្រូវបញ្ជាក់អំពីប្រភេទដីដែលស្នើសុំ ជាដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ឬជាដីសម្រាប់សង់លំនៅឋាន ឬជាដីទាំងពីរប្រភេទ ដូចមានចែងក្នុងជំពូកទី ៥នៃអនុក្រឹត្យនេះ។

គ្រួសារណាដែលពុំត្រូវបានជ្រើសរើស ជាមុខសញ្ញាអ្នកទទួលដីក្នុងផែនការសម្បទានដីសង្គមកិច្ច ថ្នាក់មូលដ្ឋាន អាចដាក់ពាក្យសុំទៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីសុំដីសម្បទាន សង្គមកិច្ច ក្នុងផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

**មាត្រា ១៣ .-**

បញ្ជីរាយនាមអ្នកសុំដីសម្បទានសង្គមកិច្ចទាំងអស់ ត្រូវបិទផ្សាយជាសាធារណៈរយៈពេលយ៉ាងតិច សាមសិប (៣០) ថ្ងៃ មុនពេលធ្វើការវាយតម្លៃ ។ កន្លែងបិទផ្សាយ ត្រូវបញ្ជាក់ក្នុងផែនការសម្បទានដី សង្គមកិច្ច ។

ក្រុមការងារថ្នាក់ស្រុក ខណ្ឌដែលមានចែងក្នុងមាត្រា ១៩ និងមាត្រា ២៦នៃអនុក្រឹត្យនេះ ត្រូវផ្តល់ជំនួយបច្ចេកទេស ក្នុងការវាយតម្លៃលើគ្រប់ពាក្យសុំ ដើម្បីកំណត់ថា អ្នកសុំដីបានបំពេញលក្ខណវិនិច្ឆ័យនៃភាពអាចជ្រើសរើសបាន ដូចបានកំណត់ក្នុងមាត្រា ១០ និងមាត្រា ១១ នៃអនុក្រឹត្យនេះ ។

ការសម្រេចយល់ព្រម ឬមិនយល់ព្រមលើពាក្យសុំ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ហេតុផល នៃការសម្រេចយល់ព្រម ឬមិនយល់ព្រមចំពោះអ្នកសុំដីម្នាក់ៗ និងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ១៤ .-**

អ្នកសុំដីដែលពុំមានឈ្មោះ នៅក្នុងផែនការសម្បទានដីសង្គមកិច្ច ហើយជឿជាក់ថា ពាក្យសុំរបស់ខ្លួន ត្រូវបានបកស្រាយមិនស្របតាមច្បាប់ភូមិបាល ឬច្បាប់ផ្សេងទៀត អាចស្នើសុំឱ្យគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ឬគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិពិនិត្យឡើងវិញ ដោយដាក់សំណើជាលាយលក្ខណ៍អក្សរក្នុងរយៈពេលម្ភៃ (២០) ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចយល់ព្រម ឬជំទាស់ទៅនឹងការស្នើសុំនោះត្រូវបានបិទផ្សាយ ដូចមានចែងក្នុងមាត្រា ១៣នៃអនុក្រឹត្យនេះ ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ឬគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវធ្វើការស៊ើបអង្កេតបណ្តឹង និងចាត់វិធានការសមស្រប ក្នុងរយៈពេលមិនឱ្យលើសពីសាមសិប (៣០) ថ្ងៃ បន្ទាប់ពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ឬគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ បានសម្រេចយល់ព្រមលើផែនការសម្បទានដីសង្គមកិច្ចដែលពាក់ព័ន្ធ ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង និងគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវរក្សាទុកបញ្ជីអ្នកសុំដីសម្បទានសង្គមកិច្ច ដែលបានដាក់ពាក្យសុំ ។

បញ្ជីឈ្មោះអ្នកដាក់ពាក្យសុំដីសម្បទានសង្គមកិច្ច ត្រូវបើកចំហជាសាធារណៈក្នុងអំឡុងពេលម៉ោងធ្វើការ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញសេចក្តីណែនាំ ស្តីពីគោលការណ៍សម្រាប់បង្កើត និងរក្សាទុកបញ្ជីឈ្មោះអ្នកសុំដី ។

ﻢ

# ជំពូកទី ៥

# ប្រភេទដីសម្បទានសង្គមកិច្ច និងលក្ខខណ្ឌនៃការកាន់កាប់

## មាត្រា ១៥ .-

ដីសម្បទានសង្គមកិច្ច អាចត្រូវបានផ្តល់ឱ្យសម្រាប់សង់លំនៅឋាន ឬសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ឬសម្រាប់គោលដៅទាំងពីរ ។

## មាត្រា ១៦ .-

ដីសម្បទានសង្គមកិច្ច ដែលត្រូវផ្តល់ឱ្យសម្រាប់សង់លំនៅឋាន មានទំហំធំបំផុតមួយពាន់ពីររយ (១.២០០) ម៉ែត្រការ៉េ ។ ប៉ុន្តែ នៅតំបន់ជនបទដែលមានលទ្ធភាពដីទំនេរ ទំហំដីសម្បទានសង្គមកិច្ច អាចដំឡើងរហូតដល់បីពាន់ប្រាំមួយរយ (៣.៦០០) ម៉ែត្រការ៉េ ។

ក្នុងករណីសមស្រប ពិសេសនៅតំបន់ទីក្រុង សម្បទានដីសង្គមកិច្ចសម្រាប់សង់លំនៅឋាន អាចផ្តល់ឱ្យតាមរូបភាពសហកម្មសិទ្ធិ ។

## មាត្រា ១៧ .-

ដីសម្បទានសង្គមកិច្ចដែលត្រូវផ្តល់ឱ្យសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ មានទំហំធំបំផុតពីរ (០២) ហិកតា ។ ប៉ុន្តែនៅក្នុងតំបន់ខ្លះ ទំហំដីសម្បទានសង្គមកិច្ច អាចដំឡើងរហូតដល់ប្រាំ (០៥) ហិកតា អាស្រ័យទៅតាមលក្ខណៈដី សក្តានុពលដី ឬប្រភេទដំណាំ និងកម្លាំងពលកម្មរបស់គ្រួសារអ្នកសុំដី ។

## មាត្រា ១៨ .-

មុខសញ្ញាអ្នកទទួលដី ត្រូវធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ជាមួយអាជ្ញាធរមានសមត្ថកិច្ចផ្តល់ដីដែលបញ្ជាក់អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់មុខសញ្ញាអ្នកទទួលដី អនុលោមតាមកម្មវិធីសម្បទានដីសង្គមកិច្ចនេះ និងចែងពីករណីលើកលែង ដូចជា ករណីប្រធានសក្តិ ឬមានជំងឺធ្ងន់ធ្ងរដែលរារាំង ដល់ការបំពេញកាតព្វកិច្ចទទួលខុសត្រូវនោះ ។ ទម្រង់ និងបែបបទសម្រាប់កិច្ចសន្យាជាលាយលក្ខណ៍អក្សរនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ក្នុងករណីផែនការសម្បទានដីសង្គមកិច្ច ដែលបានសម្រេចយល់ព្រមពុំមានចែងជាពិសេសផ្សេងពីនេះ នោះវិធាននៃការកាន់កាប់ និងប្រើប្រាស់ដីក្នុងមាត្រានេះ ត្រូវអនុវត្តទៅលើសម្បទានដីសង្គមកិច្ចទាំងអស់ ។

ហ

ប្រសិនបើគ្មានរចនាសម្ព័ន្ធលំនៅឋាន លើដីលំនៅឋាននៃសម្បទានដីសង្គមកិច្ច មុខសញ្ញាអ្នកទទួលដី ត្រូវសាងសង់យ៉ាងហោចណាស់នូវចំណែកណាមួយ នៃជម្រកស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងរយៈពេលបី (០៣) ខែ បន្ទាប់ពីទទួលបានដី ហើយសមាជិកនៃគ្រួសារនោះត្រូវរស់នៅពិតប្រាកដ និងជាអចិន្ត្រៃយ៍លើដីនោះឱ្យបានលើសពីប្រាំមួយ (០៦) ខែ ក្នុងមួយឆ្នាំ ។

មុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ចសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ត្រូវធ្វើកសិកម្មជាក់ស្តែងលើដីនោះ ក្នុងរយៈពេលដប់ពីរ (១២) ខែ បន្ទាប់ពីបានទទួលដី ហើយបន្តប្រើប្រាស់ដីនេះស្របតាមលក្ខខណ្ឌចាំបាច់ នៃកម្មវិធីសម្បទាន ។

បន្ទាប់ពីបានអនុវត្តត្រឹមត្រូវតាមកម្មវិធីសម្បទានដីសង្គមកិច្ចបានប្រាំ (០៥) ឆ្នាំ មុខសញ្ញាអ្នកទទួលដីមានសិទ្ធិកម្មសិទ្ធិលើដីនោះ និងអាចស្នើសុំប័ណ្ណកម្មសិទ្ធិ តាមនីតិវិធីដូចមានចែង នៅក្នុងសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ក្នុងករណីមុខសញ្ញាអ្នកទទួលដី ទទួលមរណភាពនៅក្នុងរយៈពេលកំពុងអនុវត្ត កម្មវិធីសម្បទានដីសង្គមកិច្ច ទាយាទក្នុងគ្រួសារនៃមុខសញ្ញាអ្នកទទួលដី អាចបន្តអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនេះរហូតដល់គ្រប់ប្រាំ (០៥) ឆ្នាំ ហើយមានសិទ្ធិកម្មសិទ្ធិលើដីនោះ ។

មុខសញ្ញាអ្នកទទួលដីមិនអាចលក់ ដូរ ជួល ឬធ្វើអំណោយដីសម្បទានសង្គមកិច្ច ក្នុងរយៈពេលប្រាំ (០៥) ឆ្នាំ ដំបូង នៃការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនេះទេ ។

ប្រសិនបើមុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ចណា ខកខានមិនបានបំពេញតាមលក្ខខណ្ឌនៃការកាន់កាប់ និងប្រើប្រាស់ដីសម្បទាននោះ ដីនេះនឹងត្រូវវិលមកជាដីរបស់រដ្ឋវិញ ដើម្បីធ្វើការបែងចែកសាជាថ្មី ។

នីតិវិធីនៃការដកហូតដីសម្បទានសង្គមកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយត្រូវចែងអំពី ៖

- ការជូនដំណឹងជាមុនក្នុងពេលវេលាសមស្របមួយ ដល់មុខសញ្ញាអ្នកទទួលដី ដែលខកខានមិនបានបំពេញតាមលក្ខខណ្ឌនៃការកាន់កាប់ និងប្រើប្រាស់ដីសម្បទានសង្គមកិច្ច
- ការទុកឱកាសឱ្យមុខសញ្ញាអ្នកទទួលដីឆ្លើយតប
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ
- គោលការណ៍ណែនាំអំពីការរើរុះ និងការកំណត់សោហ៊ុយខូចខាតសមស្រប សម្រាប់មុខសញ្ញាអ្នកទទួលដី ។

ш

# ជំពូកទី ៦
# ការគ្រប់គ្រងរដ្ឋបាល និងការអនុវត្ត

**មាត្រា ១៩ .-**

យន្តការសម្បទានដីសង្គមកិច្ច មានបេសកកម្មផ្តួចផ្តើម និងរៀបចំកម្មវិធីសម្បទានដីសង្គមកិច្ច ធ្វើការសម្រេចលើផែនការសម្បទានដីសង្គមកិច្ច និងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច សំដៅធ្វើការបែងចែកដីឱ្យប្រជាពលរដ្ឋដោយតម្លាភាព និងប្រសិទ្ធភាព ។

យន្តការសម្បទានដីសង្គមកិច្ច មានដូចតទៅ ៖

១- គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ មានអក្សរកាត់ គ.ស.ស.ជ. មានទីតាំងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

២- គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង មានអក្សរកាត់ គ.ប.ខ. មានទីតាំងនៅសាលាខេត្ត ក្រុង និងប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង ។

៣-ក្រុមការងារថ្នាក់ស្រុក ខណ្ឌ មានអក្សរកាត់ ក.ក.ស. មានទីតាំងនៅសាលាស្រុក ខណ្ឌ និងប្រើប្រាស់ត្រារបស់សាលាស្រុក ខណ្ឌ ។

៤- ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២០ .-**

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ជាស្ថាប័នកំណត់គោលនយោបាយសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ និងឋិតនៅក្រោមការត្រួតពិនិត្យ របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- ត្រួតពិនិត្យ តាមដានការផ្តល់សម្បទានដីសង្គមកិច្ច និងធ្វើការកែសម្រួលគោលនយោបាយ និងបទប្បញ្ញត្តិនានាប្រសិនបើចាំបាច់
- ពិនិត្យកែសម្រួល ឬលុបចោលការសម្រេចលើផែនការប្រើប្រាស់ និងបែងចែកដីនៅថ្នាក់ខេត្ត ក្រុង ក្នុងស្ថានភាពដែល ៖
    - មិនស្របនឹងអាទិភាពនៃការប្រើប្រាស់ដីថ្នាក់ជាតិ

• មានកំហុសបច្ចេកទេស ឬរំលោភលើបញ្ញត្តិទាំងឡាយនៃអនុក្រឹត្យ ឬច្បាប់ផ្សេងទៀត

• ផែនការដែលបានសម្រេចយល់ព្រម មិនស្របគ្នាទៅនឹងលក្ខខណ្ឌចាំបាច់នៃកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

- ផ្តល់ការគាំទ្របច្ចេកទេស ដល់ការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច
- ធ្វើសនិទានកម្មដីទំនេរ ជាមួយនឹងតម្រូវការដីសម្បទានសង្គមកិច្ច
- សម្របសម្រួលការអភិវឌ្ឍដីដែលគ្មានសេវា និងមិនអាចប្រើប្រាស់
- ផ្សារភ្ជាប់សម្បទានដីសង្គមកិច្ចទៅនឹងការបង្កើត ការប្រតិបត្តិ និងការកាត់បន្ថយសម្បទានដីសេដ្ឋកិច្ច
- ផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិដោយផ្ទាល់
- ត្រួតពិនិត្យការរីកចំរើនក្នុងការអនុវត្តការប្រើប្រាស់ដីសម្បទានសង្គមកិច្ច
- សម្របសម្រួលមធ្យោបាយ និងឱកាសសម្រាប់ដំណើរការការងារ របស់យន្តការសម្បទានដីសង្គមកិច្ចគ្រប់ថ្នាក់ ។

**មាត្រា ២១ .-**

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ មានសមាសភាពដូចតទៅ ៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ | ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន | ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ | |

ឃ

និងយុវនីតិសម្បទា ជាសមាជិក

- អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ជាអគ្គលេខាធិការ ។

ប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមជាសមាជិកតាមតម្រូវការនៃករណីនីមួយៗ ។

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ។

ប្រធាន និងសមាជិកនៃគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

## មាត្រា ២២ .-

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដឹកនាំដោយអគ្គលេខាធិការនៃគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

អគ្គលេខាធិការដ្ឋាននេះ មានមុខងារ និងភារកិច្ចដូចខាងក្រោម ៖

- លើកគោលការណ៍ត្រួតពិនិត្យ តាមដានការផ្តល់សម្បទានដីសង្គមកិច្ច និងកែសម្រួលគោលនយោបាយ និងបទប្បញ្ញត្តិនានាជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេច
- លើកគោលការណ៍លុបចោលការសម្រេច ឬកែសម្រួលផែនការប្រើប្រាស់ និងបែងចែកដីនៅថ្នាក់ខេត្តក្រុង ជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេច
- ធ្វើជាជំនួយការបច្ចេកទេស ក្នុងការធ្វើអត្តសញ្ញាណកម្មដីសម្បទានសង្គមកិច្ច ការធ្វើសុំនិទានកម្មដីទំនេរជាមួយនឹងតម្រូវការដីសម្បទាន
- រៀបចំកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដាក់ជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេច
- លើកផែនការសកម្មភាពការងារ របស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ
- អនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ
- ជំរុញការតាមដាន វាយតម្លៃលើការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ព្រមទាំងធ្វើរបាយការណ៍ទៀងទាត់ អំពីលទ្ធផលការងារ ជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ
- រៀបចំ និងសម្រួលកិច្ចប្រជុំ របស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

-បំពេញភារកិច្ចផ្សេងទៀត តាមការណែនាំរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាន ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

**មាត្រា ២៣ .-**

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ជាស្ថាប័នកំណត់គោលនយោបាយសម្បទានដីសង្គមកិច្ចថ្នាក់ខេត្ត ក្រុង ។

គណៈកម្មាធិការនេះ មានមុខងារ និងភារកិច្ច ៖

- ធានាឱ្យមានការអនុវត្តស្តង់ដារសម្រាប់ធ្វើចំណាត់ថ្នាក់ដី និងធ្វើផែនការប្រើប្រាស់ដី
- កំណត់អត្តសញ្ញាណកម្មដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ
- ត្រួតពិនិត្យ និងធ្វើសនិទានកម្មចំនួនដីទំនេរឱ្យស្របទៅនឹង សេចក្តីត្រូវការរបស់មុខសញ្ញាអ្នកទទួលដីនៅគ្រប់ស្រុក ខណ្ឌនៃខេត្ត ក្រុង
- ពិនិត្យឡើងវិញ និងវាយតម្លៃផែនការប្រើប្រាស់ដី និងផែនការសម្បទានដីសង្គមកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ បានស្នើឡើង
- សម្រេចយល់ព្រមលើការធ្វើចំណាត់ថ្នាក់ដី ការធ្វើផែនការប្រើប្រាស់ដី និងសម្រេចលើការបែងចែកដីរដ្ឋនៅថ្នាក់ខេត្ត ក្រុង
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីរៀបចំផែនការប្រើប្រាស់ដី និងធ្វើចំណាត់ថ្នាក់ដី
- សម្រេចយល់ព្រម ឬបដិសេធ ឬកែសម្រួលផែនការសម្បទានដីសង្គមកិច្ច ដែលក្រុមប្រឹក្សាឃុំ សង្កាត់ បានស្នើឡើង
- បញ្ជូនផែនការសម្បទានដីសង្គមកិច្ច និងសេចក្តីសម្រេចយល់ព្រម លើផែនការសម្បទានដីសង្គមកិច្ចទៅថ្នាក់ជាតិ ដើម្បីពិនិត្យ
- សម្របសម្រួលជាមួយក្រសួងនានា ដើម្បីរៀបចំផែនការប្រើប្រាស់ដីសម្រាប់អភិវឌ្ឍ
- សហការជាមួយអាជ្ញាធរមីន ចំពោះកន្លែងដែលមានមីន ។

ແເ

**មាត្រា ២៤ .-**

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង មានសមាសភាពដូចតទៅ ៖

- អភិបាល ឬអភិបាលរងខេត្ត ក្រុង ជាប្រធាន
- មេបញ្ជាការផ្នែកសឹករងខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ជាសមាជិក
- ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក
- ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ជាសមាជិក
- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក
- ប្រធានមន្ទីរផែនការ ជាសមាជិក
- ប្រធានមន្ទីរកិច្ចការនារី និងអតីតយុទ្ធជន ជាសមាជិក
- ប្រធានមន្ទីរបរិស្ថាន ជាសមាជិក
- ប្រធានមន្ទីរធនធានទឹក និងឧតុនិយម ជាសមាជិក
- ប្រធានមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជាសមាជិក

ប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង អាចអញ្ជើញតំណាងមន្ទីរពាក់ព័ន្ធផ្សេងទៀត ចូលរួមជាសមាជិកតាមតម្រូវការនៃករណីនីមួយៗ ។

ប្រធាន និងសមាជិកនៃគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ត្រូវបានតែងតាំងដោយប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

ប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ត្រូវតែងតាំងមន្ត្រីម្នាក់ ឬច្រើននាក់ដោយមានការយល់ព្រម របស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ដើម្បីជួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុងក្នុងកិច្ចការរដ្ឋបាល ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង មានអង្គភាពគាំទ្របច្ចេកទេសបីជាជំនួយការ ។

**មាត្រា ២៥ .-**

អង្គភាពគាំទ្របច្ចេកទេសនៃគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង រួមមាន ៖

១- អង្គភាពគាំទ្របច្ចេកទេសការងារដីធ្លី ដឹកនាំដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម

សំណង់ និងសុរិយោដី ខេត្ត ក្រុង ។ អង្គភាពនេះ មានភារកិច្ច ៖

- កំណត់អត្តសញ្ញាណកម្មដី ដែលសមស្របសម្រាប់សម្បទានដីសង្គមកិច្ច
- ធានា ការជ្រើសរើសដីសម្បទានបានត្រឹមត្រូវ និងមានតម្លាភាព ។

២- អង្គភាពគាំទ្របច្ចេកទេសការងារជ្រើសរើសមុខសញ្ញាអ្នកទទួលដី ដឹកនាំដោយអាជ្ញាធរ ខេត្ត ក្រុង ។ អង្គភាពនេះ មានភារកិច្ច ៖

- ធានា ការជ្រើសរើសមុខសញ្ញាអ្នកទទួលដីបានសមស្រប ដោយផ្អែកលើលក្ខណវិនិច្ឆ័យនៃការជ្រើសរើស
- តាមដានត្រួតពិនិត្យគម្រោងសម្បទានដីសង្គមកិច្ច និងមុខសញ្ញាអ្នកទទួលដី ។

៣- អង្គភាពគាំទ្របច្ចេកទេសការងារអភិវឌ្ឍ ដឹកនាំដោយមន្ទីរអភិវឌ្ឍន៍ជនបទ ។ អង្គភាពនេះ មានភារកិច្ច ៖

- ត្រួតពិនិត្យបញ្ហាអភិវឌ្ឍជាទូទៅ ព្រមទាំងធ្វើសនិទានកម្មចំនួនដីនឹងចំនួនអ្នកសុំដីនៅក្នុងខេត្ត ក្រុងទាំងមូល
- ធានា ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈប្រើប្រាស់ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការសម្បទានដីសង្គមកិច្ច ហើយសម្ភារៈទាំងនេះត្រូវមាននៅនឹងកន្លែងតាមកាលកំណត់ ។

សមាសភាពនៃអង្គភាពគាំទ្របច្ចេកទេស ត្រូវបានជ្រើសរើសមន្ត្រីពីសាលាខេត្ត ក្រុង និងពីមន្ទីរជុំវិញខេត្ត ក្រុង ដែលជាសមាជិករបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ។

ប្រធាន និងមន្ត្រីបម្រើការក្នុងអង្គភាពគាំទ្របច្ចេកទេស ត្រូវបានតែងតាំងដោយអភិបាលខេត្ត ក្រុង ។

ប្រសិនបើមានរចនាសម្ព័ន្ធស្រាប់ ដើម្បីបំពេញតាមតម្រូវការផ្នែកនេះ គណៈកម្មាធិការប្រើប្រាស់និងបែងចែកដីថ្នាក់ខេត្ត ក្រុង អាចប្រើប្រាស់រចនាសម្ពន្ធ័នោះ ។

**មាត្រា ២៦.-**

ក្រុមការងារថ្នាក់ស្រុក ខណ្ឌ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- អនុវត្តការងាររបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង នៅស្រុក ខណ្ឌ
- ផ្តល់ជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការធ្វើអត្តសញ្ញាណកម្មដី ធ្វើចំណាត់ថ្នាក់ដី ធ្វើផែនការប្រើប្រាស់ដី ជ្រើសរើសមុខសញ្ញាអ្នកទទួលដី និងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច
- ធានា ការបែងចែកដីសម្បទានសង្គមកិច្ចថ្នាក់មូលដ្ឋានមានប្រសិទ្ធភាព និងតម្លាភាព ។

ພ

**មាត្រា ២៧ .-**

សមាសភាពនៃក្រុមការងារថ្នាក់ស្រុក ខណ្ឌ មានដូចតទៅ ៖

- អភិបាល ឬអភិបាលរងស្រុក ខណ្ឌ ជាប្រធាន
- ប្រធានការិយាល័យស្រុក ខណ្ឌ ដែលជាតំណាងក្រសួង ស្ថាប័នក្នុងសមាសភាពរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ដូចមានចែងក្នុងមាត្រា ២១នៃអនុក្រឹត្យនេះ ជាសមាជិក
- តំណាងអាជ្ញាធរមូលដ្ឋាន ជាសមាជិក

ប្រធាន និងសមាជិកក្រុមការងារនេះ ត្រូវតែងតាំងដោយអភិបាលខេត្ត ក្រុង ។

**មាត្រា ២៨ .-**

ក្រុមប្រឹក្សាឃុំ សង្កាត់ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- ផ្តួចផ្តើម និងពិចារណាផែនការសម្បទានដីសង្គមកិច្ច ឱ្យស្របតាមនីតិវិធីនៃការអភិវឌ្ឍឃុំ សង្កាត់
- អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយមានការគាំទ្របច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក ខណ្ឌ
- ទទួលខុសត្រូវក្នុងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ក្នុងចំណោមអ្នកដាក់ពាក្យសុំដី
- ទទួលខុសត្រូវក្នុងការបែងចែកដីដោយត្រឹមត្រូវ និងដោយប្រសិទ្ធភាព ។

## ជំពូកទី ៧

## ប្រភពធនធាន

**មាត្រា ២៩ .-**

ថវិកាសម្រាប់ដំណើរការរបស់យន្តការសម្បទានដីសង្គមកិច្ច ឋិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ៣០ .-**

ស្របតាមប្រព័ន្ធថវិកាឯកភាព ធនធាន និងថវិការបស់យន្តការសម្បទានដីសង្គមកិច្ច បានមកពី ៖

- ថវិកាជាតិ
- ហិរញ្ញប្បទានបានមកពីក្នុង និងក្រៅប្រទេស ឬអង្គការផ្ដល់ជំនួយអន្តរជាតិ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៣១ .-**

គោលការណ៍ណែនាំអនុវត្តអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ៣២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអភិបាលខេត្ត ក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ មីនា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្ដាល
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៣៣
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៣៧៨.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយការងារ** ជូននាយទាហាន នាយទាហានរង និងពលទាហានចំណុះបញ្ជាការដ្ឋានកងទ័ពជើងគោក ដែលមានស្នាដៃល្អក្នុងការបំរើជាតិ មាតុភូមិ ដូចមានរាយនាមខាងក្រោម ÷

### ក-មេដាយមាសការងារចំនួន ១៣គ្រឿង

| | | | | |
|---|---|---|---|---|
| ១-ឧត្តមសេនីយ៍ទោ | **ហ្គួត** | **ឈាង** | អត្តលេខ ០០០១៣៦ | មេបញ្ជាការយោធភូមិភាគទី ១ |
| ២-វរសេនីយ៍ឯក | **ឈ្នួរ** | **ច័ន្ទធឿន** | អត្តលេខ ០០០៨៦៤ | មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៣-វរសេនីយ៍ទោ | **ប៊ិ្ញ** | **សារ៉ែម** | អត្តលេខ ០០០៨៦៦ | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៤-វរសេនីយ៍ទោ | **ធន** | **ធឿន** | អត្តលេខ ០០០៨៦៧ | មេបញ្ជាការរង និងជានាយសេនាធិការ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៥-វរសេនីយ៍ទោ | **យ៉ិចំ** | **ភួងម៉ារ៉ា** | អត្តលេខ ០០១២៣១ | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |

| | | | | |
|---|---|---|---|---|
| ៦-វរសេនីយ៍ទោ | គីម | ថេន | អត្តលេខ ០០៤៩៦២ | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៧-អនុសេនីយ៍ឯក | ឃួ | សុខផាន់ | អត្តលេខ ០១០៣៩៨ | នាយការិយាល័យទី១ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៨-អនុសេនីយ៍ឯក | ប៉ាត | យោង | អត្តលេខ ០១០៣៩៩ | នាយការិយាល័យទី២ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៩-អនុសេនីយ៍ឯក | នៅ | ពុំ | អត្តលេខ ០១៩៣៣៩ | នាយលេខាធិការដ្ឋាន តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១០-អនុសេនីយ៍ឯក | គង | សារឿន | អត្តលេខ ០១៩៣៤៧ | នាយការិយាល័យហិរញ្ញវត្ថុ តំបន់ប្រតិបត្តិការ សឹករងកំពង់ឆ្នាំង |
| ១១-អនុសេនីយ៍ឯក | កេត | យ៉យ | អត្តលេខ ០១០៤០៦ | មេបញ្ជាការ វរសេនាតូចលេខ១ តំបន់ប្រតិបត្តិការ សឹករងកំពង់ឆ្នាំង |
| ១២-អនុសេនីយ៍ឯក | សំ | ចាន់ថន | អត្តលេខ ០១០៤១០ | មេបញ្ជាការស្រុកកំពង់លែង តំបន់ប្រតិបត្តិការ សឹករងកំពង់ឆ្នាំង |
| ១៣-អនុសេនីយ៍ទោ | គង់ | ស៊ីណេត | អត្តលេខ ០១៩៣៣៨ | នាយរងលេខាធិការដ្ឋាន តំបន់ប្រតិបត្តិការ សឹករងកំពង់ឆ្នាំង |

## ខ-មេដាយប្រាក់ការងារចំនួន ២៦គ្រឿង

| | | | | |
|---|---|---|---|---|
| ១-វរសេនីយ៍ទោ | នន្ទ | រាសី | អត្តលេខ ០០០៨៦៩ | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ២-វរសេនីយ៍ទោ | យូ | ចរៈ | អត្តលេខ ០០១៩៣៤ | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៣-វរសេនីយ៍ត្រី | ឯម | លី | អត្តលេខ ០០៤៤៤៧ | នាយរង ផ្នែកលេខាធិការដ្ឋាន បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក |
| ៤-វរសេនីយ៍ត្រី | អម | សុធនមុន្នី | អត្តលេខ ០០២៩០៩ | នាយរង ផ្នែកប្រតិបត្តការសឹក បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក |
| ៥-វរសេនីយ៍ត្រី | នួរ | សីរីទ្ធ | អត្តលេខ ០០៣១៩១ | នាយសេនាធិការរង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៦-វរសេនីយ៍ត្រី | គង់ | ថាន | អត្តលេខ ០០៣១៩០ | នាយសេនាធិការរង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៧-អនុសេនីយ៍ឯក | សុខ | សុផាត | អត្តលេខ ០០៩៥៤៨ | មេបញ្ជាការរង វរសេនាតូចលេខ៧៧ សំណង់អាគារ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក |
| ៨-អនុសេនីយ៍ឯក | ឃ្លោក | សារិ | អត្តលេខ ០០៩៥៥៩ | នាយរងផ្នែកបទបញ្ជា បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក |
| ៩-អនុសេនីយ៍ឯក | ឈិត | រាលសុម៉ារ៉ា | អត្តលេខ ០១១៤៧៥ | នាយរងផ្នែកសំណង់អាគារ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក |

១០-អនុសេនីយ៍ឯក ឌួល ផល អត្តលេខ ០១៧៦០៧ នាយរងផ្នែកហ្វឹកហ្វឺន បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

១១-អនុសេនីយ៍ឯក ហ៊្វួត សារិម អត្តលេខ ០១០៤០២ នាយការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករង កំពង់ឆ្នាំង

១២-អនុសេនីយ៍ឯក សូ រដ្ឋា អត្តលេខ ០១០៤១៤ មេបញ្ជាការស្រុកកំពង់ឆ្នាំង តំបន់ប្រតិបត្តិការ សឹករងកំពង់ឆ្នាំង

១៣-អនុសេនីយ៍ឯក ឈឹម ម៉េន អត្តលេខ ០១០៤០៥ មេបញ្ជាការស្រុកទឹកផុស តំបន់ប្រតិបត្តិការ សឹករងកំពង់ឆ្នាំង

១៤-អនុសេនីយ៍ឯក សេង សារឿន អត្តលេខ ០១០៤១៣ មេបញ្ជាការស្រុកសាមគ្គីមានជ័យ តំបន់ប្រតិបត្តិការ សឹករងកំពង់ឆ្នាំង

១៥-អនុសេនីយ៍ឯក សោម សំអូល អត្តលេខ ០១០៤០៤ មេបញ្ជាការស្រុកបរិបូរ តំបន់ប្រតិបត្តិការ សឹករងកំពង់ឆ្នាំង

១៦-អនុសេនីយ៍ឯក អ៊ុំ សុគា អត្តលេខ ០១០៤០០ នាយការិយាល័យទី៣ តំបន់ប្រតិបត្តិការ សឹករងកំពង់ឆ្នាំង

១៧-អនុសេនីយ៍ទោ សំ សោភា អត្តលេខ ០១៩៩៦៥ ជំនួយការកំព្យូទ័រ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

១៨-អនុសេនីយ៍ទោ ហ៊ុល ឧត្តិ អត្តលេខ ០២៧៧៣៨ មេបញ្ជាការរង វរសេនាតូចលេខ ៧៧ សំណង់អាគារ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

១៩-អនុសេនីយ៍ទោ ញ៉ែម ឡេង អត្តលេខ ០៣៣១៥១ ជំនួយការរបៀប បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

២០-អនុសេនីយ៍ទោ គឹម សុផាត អត្តលេខ ០១៥៣៦១ មេបញ្ជាការ អនុសេនាធំឯករាជ្យ តំបន់ប្រតិបត្តិការ សឹករងកំពង់ឆ្នាំង

២១-អនុសេនីយ៍ត្រី អ៊ុង ម៉ាង អត្តលេខ ២២២៤១ ជំនួយការលេខា បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

២២-អនុសេនីយ៍ត្រី ផាត់ នៃ អត្តលេខ ០២៧២២៧ ជំនួយការគ្រឿងចក្រ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

២៣-អនុសេនីយ៍ត្រី ចាន់ ធូរ៉ា អត្តលេខ ០៣៩៧៣ មេបញ្ជាការរង កងដឹកជញ្ជូន បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

២៤-នាយចំណង់ ផៃ ផារិន អត្តលេខ ០៩៨៨៦៦ ជំនួយការសុខាភិបាល បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

២៥-នាយចំណង់ ភួង សុភ័ណ្ឌ អត្តលេខ ០៤៩២៦១ មេបញ្ជាការរង អនុសេនាធំទី២ វរសេនាតូចលេខ៧៦ ស្ពានថ្នល់ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

២៦-នាយឯក សួខ សារ៉េត អត្តលេខ ២២១៧១៩ ពលទាហាន វរសេនាតូចលេខ៧៦ ស្ពានថ្នល់ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

## គ-មេដាយសិរីវឌ្ឍនៈមាសចំនួន ៣១គ្រឿង

១-វរសេនីយ៍ត្រី ឯម ចិចិត្រ អត្តលេខ ០០១៧២៥ នាយសេនាធិការរង បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

២-វរសេនីយ៍ត្រី ប៉ែន សុវណ្ណារ អត្តលេខ ០០៣១៩២ នាយសេនាធិការរង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង

៣-វរសេនីយ៍ត្រី ហ៊ុយ អ៊ីម៉ារ៉ា អត្តលេខ ០០៣៥១៥ នាយសេនាធិការរង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង

៤-វរសេនីយ៍ត្រី ស៊ួន សារ៉ាន អត្តលេខ ០០២៩១៥ នាយសេនាធិការរង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង

៥-អនុសេនីយឯក ចាន់ សុផល អត្តលេខ ០១៧៦០១ នាយរងផ្នែកហិរញ្ញ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

៦-អនុសេនីយឯក នេង ម៉ុនឡុង អត្តលេខ ០១៦៨៤២ នាយរងផ្នែកបុគ្គលិក បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

៧-អនុសេនីយឯក ហេង បញ្ញា អត្តលេខ ០១៧៦០៦ នាយរងផ្នែកឃោសនាពត៌មាន បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

៨-អនុសេនីយឯក ស៊ិន ឌន អត្តលេខ ០១៧៦៣៥ នាយរងផ្នែកសំណង់យុទ្ធសាស្ត្រ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

៩-អនុសេនីយឯក នោគ សុវឌ្ឍី អត្តលេខ ០១៧៥៩៧ នាយឃ្លាំង បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

១០-អនុសេនីយឯក មុំ ហឿន អត្តលេខ ០១៧៥៩៨ មេបញ្ជាការរង វរសេនាតូចលេខ៧៧ សំណង់អាគារ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

១១-អនុសេនីយ៍ឯក នេង សួល អត្តលេខ ០១៩៣៥៨ នាយការិយាល័យជីវពល តំបន់ប្រតិបត្តិការ សឹករងកំពង់ឆ្នាំង

១២-អនុសេនីយ៍ឯក ទេព សារី អត្តលេខ ០១០៤០៨ មេបញ្ជាការស្រុករលាប្អៀរ តំបន់ប្រតិបត្តិការ សឹករងកំពង់ឆ្នាំង

១៣-អនុសេនីយ៍ឯក អ៊ុំ សំអាត អត្តលេខ ០១០៤១១ មេបញ្ជាការស្រុកជលគីរី តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង

១៤-អនុសេនីយ៍ឯក អឿត ម៉ុច អត្តលេខ ០១០៤១២ មេបញ្ជាការស្រុកកំពង់ត្រឡាច តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង

១៥-អនុសេនីយ៍ទោ សាខ ឃឿន អត្តលេខ ០២៧២៣៥ មេបញ្ជាការ កងអនុសេនាធំការពារ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

១៦-អនុសេនីយ៍ទោ មាស ឡុច អត្តលេខ ០២៧១៥៨ នាយរងឃ្លាំង បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

១៧-អនុសេនីយ៍ទោ ហោ យ៉ុន អត្តលេខ ០១៧៦១៩ មេបញ្ជាការរង វរសេនាតូចលេខ៧៦ ស្ពានថ្នល់ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

១៨-អនុសេនីយ៍ទោ ព្រហ្ម សារ៉េត អត្តលេខ ០២៧១៦១ ជំនួយការរថយន្ត បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

១៩-អនុសេនីយ៍ទោ មាស ខ្សៃ អត្តលេខ ០២៧១៨៥ មេបញ្ជាការរងកងទី១ វរសេនាតូចលេខ៧៨ វត្តភាំង បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

២០-អនុសេនីយ៍ទោ ម៉ើ ប៊ុនធឿន អត្តលេខ ០១៧៦២០ មេបញ្ជាការរង វរសេនាតូចលេខ៧៨ វត្តភាំង បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

២១-អនុសេនីយ៍ទោ ឌួន សុផាត អត្តលេខ ០៣៩២៦៦ មេបញ្ជាការរង កងអនុសេនាធំទី ១ វរសេនាតូចលេខ៧៨ វត្តភាំង បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

២២-អនុសេនីយ៍ទោ តែច គីមលី អត្តលេខ ០១៥៣៨៣ នាយរងការិយាល័យទី១ តំបន់ប្រតិបត្តិការសឹករង កំពង់ឆ្នាំង

២៣-អនុសេនីយ៍ទោ អ៊ុំ ចាន់លី អត្តលេខ ០១៥៣៤១ នាយគិលានដ្ឋាន តំបន់ប្រតិបត្តិការសឹករង កំពង់ឆ្នាំង

២៤-អនុសេនីយ៍ទោ ជិន សារុន អត្តលេខ ០១៥៥៣៤ នាយរងការិយាល័យទី ៤ តំបន់ប្រតិបត្តិការសឹករង កំពង់ឆ្នាំង

២៥-អនុសេនីយ៍ទោ ហែម គង់ អត្តលេខ ០៤០៨៦៥ នាយក្រុមហិរញ្ញវត្ថុ តំបន់ប្រតិបត្តិការសឹករង កំពង់ឆ្នាំង

២៦-អនុសេនីយ៍ទោ ប៊ិន ប៊ុនរិទ្ធ អត្តលេខ ០២៧៨៧៩ នាយផ្នែកបញ្ជូនសារ តំបន់ប្រតិបត្តិការសឹករង កំពង់ឆ្នាំង

២៧-អនុសេនីយ៍ត្រី **និត សារិន** អគ្គលេខ ០២៧២៣០ មេកងដឹកជញ្ជូន បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

២៨-នាយចំណង់ **អ៊ុំ ម៉ាន** អគ្គលេខ ២២២៤៥០ ជំនួយការយានយន្ត បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

២៩-ព្រិន្ទបាលឯក **ហាឡុ ហឿន** អគ្គលេខ ០៩៩៤៧១ នាយទាហានរង បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

៣០-ព្រិន្ទបាលឯក **ទឹម ភាត់** អគ្គលេខ ០២១៧៧៦ នាយទាហានរង បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

៣១-ព្រិន្ទបាលឯក **ឡូខ ឈិន** អគ្គលេខ ០៥១៣៣០ ជំនួយការព័ត៌មាន បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និងអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំង :

១_លោក **ឃិន ឡាត់** ជាអធិការ នៃអគ្គាធិការដ្ឋាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

២_លោក **ថាយ ស៊ុនហ៊ាង** ជាអធិការ នៃអគ្គាធិការដ្ឋាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៣*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៤០ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សំ រេ ច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ៧៣ រូប នៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ឆ្នាំ ២០០២ ដូចមានរាយនាម ខាងក្រោមនេះ :-

**ក_មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១-លោក | **ទឹម** | **សុខៃ** | ប្រធានក្រុមតំរោង នៃអគ្គលេខាធិការដ្ឋានកំណែទំរង់រដ្ឋបាល |
| ២-លោក | **ឈឹម** | **ផាវីន** | ប្រធានក្រុមតំរោង នៃអគ្គលេខាធិការដ្ឋានកំណែទំរង់រដ្ឋបាល |
| ៣-លោក | **អ៊ុក** | **សំបូរ** | ប្រធានក្រុមតំរោង នៃអគ្គលេខាធិការដ្ឋានកំណែទំរង់រដ្ឋបាល |
| ៤-លោក | **នួច** | **សីហាយ** | ជំនួយការផ្ទាល់ ក្រុមប្រឹក្សាអ្នកច្បាប់ |
| ៥-លោក | **ជា** | **អៀង** | ប្រធាននាយកដ្ឋាន អាជ្ញាធរមីន |
| ៦-លោក | **ពេជ** | **ឌុន** | អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិទន្លេមេគង្គ |
| ៧-លោក | **ចាប** | **សុជាវិន្ឋ** | ប្រធាន នាយកដ្ឋានអាស៊ាន |
| ៨-លោកស្រី | **ណី** | **សុឃីម** | ប្រធានផ្នែកអាជីវកម្មព្រៃឈើ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ |
| ៩-លោក | **ជា** | **វ៉ាន់ដេត** | អនុប្រធាននាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ |

**ខ_មេដាយប្រាក់ការងារ :**

| | | | |
|---|---|---|---|
| ១-លោក | **គិត** | **ឃៀង** | ស្នើប្រធាននាយកដ្ឋាន លេខាធិការដ្ឋានមេធាវីរាជរដ្ឋាភិបាល |
| ២-លោក | **ញៀម** | **សាត** | ស្នើប្រធាននាយកដ្ឋាន នៃនាយកដ្ឋានតំកល់ឯកសារ |
| ៣-លោក | **ហុង** | **លាងហេង** | អនុប្រធានផ្នែកនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| ៤-លោក | **សេង** | **សាវ៉ន** | អនុប្រធាននាយកដ្ឋាន ពត៌មានសារគមនាគមន៍ |
| ៥-លោក | **សុន** | **ពិសិដ្ឋ** | ជំនួយការ ក្រុមប្រឹក្សាអ្នកច្បាប់ |
| ៦-លោក | **នួច** | **សំអាត** | អនុប្រធាននាយកដ្ឋាន នៃគណៈកម្មការអចិន្ត្រៃយ៍ រៀបចំបុណ្យជាតិ |
| ៧-លោក | **ពឹង** | **ស៊ីចុន្ថា** | អនុប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានប្រឆាំងគ្រឿងញៀន |
| ៨-លោក | **ញាណ** | **វិបុល** | អនុប្រធាននាយកដ្ឋាន អាស៊ាន |
| ៩-លោក | **ឡុង** | **ពៅច្រាដ្ឋា** | អនុប្រធាននាយកដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |

| | | | |
|---|---|---|---|
| ១០-លោក | អ៊ុច | ខាត់ | អនុប្រធានផ្នែករដ្ឋបាល នៃរាជបណ្ឌិតសភាកម្ពុជា |
| ១១-លោក | សេង | សំអឿន | អនុប្រធានផ្នែកផែនការ នៃរាជបណ្ឌិតសភាកម្ពុជា |
| ១២-លោក | ចាន់ | ម៉ុន្នី | អនុប្រធានផ្នែក នៃរាជបណ្ឌិតសភាកម្ពុជា |
| ១៣-លោក | ឡុង | រ៉ាឌូច | អនុប្រធានផ្នែករដ្ឋបាល នៃរាជបណ្ឌិតសភាកម្ពុជា |
| ១៤-លោកស្រី | ស៊ុំ | ម៉ូនីកា | អនុប្រធាននាយកដ្ឋានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការ អភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា |

**គ-មេដាយសេរីវឌ្ឍនភាពសំរិទ្ធ :**

| | | | |
|---|---|---|---|
| ១-លោក | ហាម | សេងតា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានឧស្សាហកម្ម និងសំណង់ |
| ២-លោក | ជុំ | ទ៉ាត | មន្ត្រី អាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ វិស័យបច្ចេក-វិទ្យា គមនាគមន៍ ពត៌មានវិទ្យា |
| ៣-លោក | ឈុន | លីម | ប្រធានការិយាល័យ នៃនាយកដ្ឋានតំកល់ឯកសារ |
| ៤-លោកស្រី | អ៊ុក | ឌូច | អនុប្រធានក្រុមគំរោង អគ្គលេខាធិការដ្ឋានកំណែទំរង់រដ្ឋបាល |
| ៥-លោក | ប៉ែន | គីមប៊ុន | អនុប្រធានការិយាល័យ នៃនាយកដ្ឋានអប់រំ វប្បធម៌ សង្គមកិច្ច |
| ៦-លោក | សួស | ទិសុទ្ធ | អនុប្រធានក្រុមរដ្ឋបាល នៃអគ្គលេខាធិការដ្ឋាន កំណែទំរង់រដ្ឋបាល |
| ៧-លោក | ឈឹម | ចាន់ណារ៉ុង | អនុប្រធានការិយាល័យ នៃនាយកដ្ឋាន រដ្ឋបាល |
| ៨-កញ្ញា | គង់ | បូផាណា | អនុប្រធានការិយាល័យ នៃនាយកដ្ឋាន រដ្ឋបាល |
| ៩-កញ្ញា | ម៉ែន | រតនា | មន្ត្រី នាយកដ្ឋានរដ្ឋបាល |
| ១០-លោក | ហៃ | សំអុល | អនុប្រធានការិយាល័យ នាយកដ្ឋានសេវាកុំព្យូទ័រ |
| ១១-លោកស្រី | អ៊ុង | ចាន់ធី | អនុប្រធានការិយាល័យ នាយកដ្ឋានសេវាកុំព្យូទ័រ |
| ១២-លោកស្រី | សាន់ | សុវត្ថារី | មន្ត្រី នាយកដ្ឋានសេវាកុំព្យូទ័រ |
| ១៣-លោកស្រី | ហាម | ដារ៉ែន | មន្ត្រី នាយកដ្ឋានសេវាកុំព្យូទ័រ |
| ១៤-លោកស្រី | ម៉ៅ | ច័ន្ទថា | មន្ត្រី នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ១៥-កញ្ញា | អ៊ូក | ដាវី | ប្រធានការិយាល័យ នាយកដ្ឋានពត៌មាន និងសារគមនាគមន៍ |
| ១៦-លោកស្រី | យឹម | ស៊ីថា | មន្ត្រី នាយកដ្ឋាន ពិធីការ |
| ១៧-លោកស្រី | នេត | សារ៉េម | មន្ត្រី នាយកដ្ឋានពិធីការ |
| ១៨-កញ្ញា | តឹក | ម៉ុល្លិការី | មន្ត្រី នាយកដ្ឋានពិធីការ |
| ១៩-លោកស្រី | ឌុច | ចន្ធី | មន្ត្រី នាយកដ្ឋានពិធីការ |
| ២០-លោកស្រី | ឡាយ | ស៊ីណារ៉ាត | មន្ត្រី នាយកដ្ឋានពិធីការ |
| ២១-លោកស្រី | ឯក | ម៉ាលី | មន្ត្រី នាយកដ្ឋានពិធីការ |
| ២២-លោក | យឹម | សុគន្ធី | អនុប្រធានការិយាល័យ អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល |
| ២៣-លោក | ហុក | ម៉ុនរ៉េង | អនុប្រធានការិយាល័យ ទទួលពាក្យបណ្តឹង |
| ២៤-លោក | កែវ | កណ្ណារិទ្ធ | មន្ត្រី លេខាធិការដ្ឋានមេធាវី រាជរដ្ឋាភិបាល |
| ២៥-លោក | សៅ | សុផាត | អនុប្រធានការិយាល័យ គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ |
| ២៦-លោកស្រី | ជា | វុណ្ណា | អនុប្រធានការិយាល័យ គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ |
| ២៧-លោក | អ៊ឹម | សុផល | មន្ត្រី គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ |
| ២៨-លោក | មាស | ហ៊ីត | អនុប្រធានការិយាល័យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ២៩-កញ្ញា | ហាង្ស | បូទ៉ារី | អនុប្រធានការិយាល័យ នាយកដ្ឋានសរុប |
| ៣០-លោក | ស៊ាង | គីមចន់ | មន្ត្រី នាយកដ្ឋានសរុប |
| ៣១-លោកស្រី | អ៊ុច | ចាន់ណា | មន្ត្រី នាយកដ្ឋានសរុប |
| ៣២-លោក | យ៉ិន | ណេន | ប្រធានការិយាល័យ នាយកដ្ឋានបុគ្គលិក |
| ៣៣-លោក | កង | ស្រួយ | អនុប្រធានការិយាល័យ នាយកដ្ឋានបុគ្គលិក |
| ៣៤-លោក | តៅ | ចន្ទណ្ណី | មន្ត្រី នាយកដ្ឋានពាណិជ្ជកម្ម |
| ៣៥-លោក | រាត់ | សុខជា | មន្ត្រី នាយកដ្ឋានពាណិជ្ជកម្ម |

៣៦-លោកស្រី **រស់ សុខាល** ប្រធានការិយាល័យ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច
៣៧-លោក **អ៊ុក សារឿន** អនុប្រធានការិយាល័យ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច
៣៨-លោកស្រី **មាស តុន្នី** អនុប្រធានការិយាល័យ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច
៣៩-លោក **ឈៅ ឆេង** អនុប្រធានការិយាល័យ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច
៤០-លោកស្រី **អ៊ឹម ចន្ទសេរី** អនុប្រធានការិយាល័យ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច
៤១-លោក **សួន ថុល** មន្ត្រី នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច
៤២-លោក **មាស ពុទ្ធារិន** មន្ត្រី នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច
៤៣-លោក **ទ៊ាល់ សារឡុង់** មន្ត្រី នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច
៤៤-លោក **ឈុំ ទិបុល** មន្ត្រី នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច
៤៥-លោកស្រី **ញ៉ឹក រ៉ានី** អនុប្រធានការិយាល័យ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច
៤៦-លោកស្រី **ផន ទ៊ាន់នី** អនុប្រធានការិយាល័យ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច
៤៧-លោក **សាយ ឆាន** អនុប្រធានការិយាល័យ ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង
៤៨-លោក **ឃាង ចំនួនតារា** អនុប្រធាន ផ្នែកបណ្តុះបណ្តាល រាជបណ្ឌិតសភាកម្ពុជា
៤៩-លោក **តាន់ សុគន្ធា** មន្ត្រី រាជបណ្ឌិតសភាកម្ពុជា
៥០-លោក **ស៊ុយ សុំថុន** ប្រធានការិយាល័យ នាយកដ្ឋាន កសិកម្ម

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៤១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

### សំរេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ប្រគេនព្រះតេជគុណ **គ្រូច អ៊ឹម** ព្រះវិន័យធរ អនុគណខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ដែលបានខិតខំអំពាវនាវពុទ្ធបរិស័ទ នៅក្នុង និងក្រៅប្រទេស ព្រមទាំងបច្ច័យផ្ទាល់របស់ព្រះអង្គ យកមកកសាងកុដិថ្មពីរជាន់ នៅវត្តនាគវ័ន សង្កាត់បឹងកក់ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ និង កសាង កុដិឈើ ជួសជុលខឿនព្រះវិហារ ធ្វើចេតិយ៍ និង សមិទ្ធផលផ្សេងៗទៀត នៅក្នុងវត្ត ឃ្លោយ ឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ចំណាយអស់បច្ច័យសរុប ចំនួន ៨៧.៩៨៦ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៤២ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី

### សំរេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ចំនួន១៣គ្រឿង ជូនបុគ្គល និង អង្គភាព ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច បង្ក្រាបបទល្មើស បំផ្លិចបំផ្លាញបេតិកភណ្ឌជាតិ ព្រមទាំងឃាត់ទុក និងប្រមូលបានរូបចំលាក់ ដែលជាវត្ថុបូរាណ យកមកប្រគល់អោយអភិរក្សអង្គរ-សៀមរាប ថែរក្សាទុកជាសម្បត្តិជាតិ ចំនួន ៩៨៧ ដុំ-ផ្ទាំង ដូចមានរាយនាមខាងក្រោមនេះ :-

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ទោ | **ជា** | **ម៉ន** | មេបញ្ជាការយោធភូមិភាគទី ៤ |
| ២-លោក | **ឆេត** | **សំអាន** | មេបញ្ជាការ អ៩០ |
| ៣-វរសេនីយ៍ឯក | **តាន់** | **ចាយ** | ស្នងការនគរបាលពិសេសការពារបេតិកភណ្ឌ |
| ៤-វរសេនីយ៍ឯក | **ឃឹម** | **ប៊ុនសុខ** | មេបញ្ជាការតំបន់ ប្រតិបត្តិការសឹករងសៀមរាប |
| ៥-វរសេនីយ៍ឯក | **ម៉ឹម** | **សាម៉ុន** | មេបញ្ជាការកងរាជអាវុធហត្ថ ខេត្តសៀមរាប |
| ៦-វរសេនីយ៍ឯក | **នួន** | **បូផល** | ស្នងការនគរបាល ខេត្តសៀមរាប |
| ៧-វរសេនីយ៍ទោ | **ខេង** | **ស៊ី** | ស្នងការរង នគរបាល ខេត្តសៀមរាប |
| ៨-លោក | **ម៉ក់** | **សំការ** | អភិបាលស្រុកសូត្រនិគម |
| ៩-លោក | **កៅ** | **សុគ័ណ** | អភិបាល ស្រុកជីក្រែង |

១០-សាលាខេត្ត សៀមរាប

១១-សាលាស្រុកបន្ទាយស្រី

១២-សាលាស្រុកស្វាយលើ

១៣-សាលាស្រុកពួក

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មី៣ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

95

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៤ អនក្រ.បក - ១១

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សំ រេ ច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០២គ្រឿង ជូនតំណាងអង្គការ **JHP** ជប៉ុន ចំនួន០២រូប ដែលបានផ្តល់អំណោយជាថវិកា សំរាប់ជួយកសាង អគារសិក្សា០១ខ្នង មាន០៦បន្ទប់ រួមទាំងតុ កៅអីសិស្ស-គ្រូ ក្តារខៀន បង្គន់អនាម័យ អណ្តូងទឹក ជូនសាលាបឋមសិក្សា ឈើទាលភ្លោះ ឃុំស្វាយរំពារ ស្រុកមុខកំពូល ខេត្តកណ្តាល ដូចមាននាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១-លោកស្រី | **អូសាណៃ** | **មីអេគុ** | ថវិកា | ២០.២១៥ **USD** |
| ២-លោកស្រី | **កូដាម៉ា** | **តូស៊ីកូ** | ថវិកា | ១៦.២៥៥ **USD** |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៤៤ អនក្រ.បក - ៩៩

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ស ំ រេ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា ០១ ខ្នង ផ្ទះសំណាក់គ្រូបង្រៀន ០៣ ខ្នង និង ជួយឧបត្ថម្ភប្រចាំខែ ដល់គ្រូបង្រៀន ០៤ រូប នៅសាលាបឋមសិក្សាឡៃមធៀន ក្នុងស្រុកគិរីសាគរ ខេត្តកោះកុង ចំណាយអស់ទឹកប្រាក់ ចំនួន ២៥.៧០០ USD និង មួយ ខែ ១២.០០០ បាត ដូចមានរាយនាមខាងក្រោម ÷

១-លោក **ឡុង ជីម** ហៅ **សៀង ឡឹក** បញ្ជាការនគរបាលការពារព្រំដែនទឹក ប្រចាំការកោះម្នាស់

២-លោកស្រី **នូ ហួន**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៣ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៤៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០២ រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសាលាឆាន់ ០១ ខ្នង ធ្វើពីបេតុង នៅវត្តធ្លា ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម ដូចមាននាមខាងក្រោម ÷

១-លោកតា **គី** បរិច្ចាគថវិកា ១២.៨៥០ USD

២-លោកយាយ **នាង ទ៉ា** បរិច្ចាគថវិកា ១២.000 USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៨៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូនលោក **សូរ ណាត** និង ភរិយាដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន សំរាប់ចូលរួមកសាង សមិទ្ធផលផ្សេងៗ ក្នុងវត្តខេមរ៉ែន ឃុំសំបួរមាស ស្រុកកំពង់ចាម ខេត្តកំពង់ចាម ចំណាយអស់ទឹកប្រាក់ ចំនួន ១១.៥៥០ USD ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៤៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

### ស ំ រេ ច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយប្រាក់ស្ថាបនាជាតិ** ចំនួន០២គ្រឿង ជូនតំណាងអង្គការសប្បុរសធម៌ជប៉ុន ចំនួន ០២រូប ដែលបានផ្តល់ថវិកា សំរាប់ជួយកសាងអគារសិក្សា ០១ខ្នង ជូនសាលាបឋមសិក្សា ឧបសម្ព័ន្ធ អូរជួបថ្មី ក្នុងឃុំសឿ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមាននាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១-លោកឪពុក | **ហ្គោតូ ហ្វូមិអូ** | (GOTO FUMIO) | ថវិកា | ៥.៩៨៤,៥០ USD |
| ២-លោក | **មាស ប៊ុនរ៉ា** | (MEAS BUNRA) | ថវិកា | ៥.៩៨៤,៥០ USD |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### ស ម្រេ ច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូនលោក **MARNIX NIEMEIJER** សប្បុរសជន ជនជាតិហូឡង់ ដែលបានជួយកសាងអគារសិក្សា ០១ខ្នង ជូនសាលាបឋមសិក្សា វត្តថ្មី ឃុំគោកស្រុក ស្រុកតំបែរ ខេត្តកំពង់ចាម ចំណាយអស់ថវិកា ចំនួន ១៧.៦៦១ USD ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៧៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សំរេច

**មាត្រា ១** : ត្រូវបានផ្ទេរភារកិច្ចលោក **ផាត់ មុនី** បច្ចុប្បន្នសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម មកជានាយកសាលាជាតិកសិកម្មព្រែកលៀប នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ_កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ២៥០ អនក្រ-បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

**ស ំ រ េ ច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន១១រូប នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកណ្តាល ដែលមានស្នាដៃល្អ ក្នុងការស្តារ និងអភិវឌ្ឍន៍ វិស័យសិល្បៈវប្បធម៌ជាតិ រយៈពេល៥ឆ្នាំ " ១៩៩៩-២០០៣ " ដូចមានរាយនាមខាងក្រោមនេះ :-

**ក_មេដាយមាសការងារ :**

| | | |
|---|---|---|
| ១-លោក | **អ៊ុក ឈាងលី** | ប្រធានការិយាល័យរដ្ឋបាល - បុគ្គលិក មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកណ្តាល |
| ២-លោក | **ជា លក្ខិណា** | ប្រធានការិយាល័យសិល្បៈ និងទស្សនីយភាព មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកណ្តាល |
| ៣-លោក | **កង ចណ្ណា** | ប្រធានការិយាល័យអភិវឌ្ឍន៍ វប្បធម៌ មន្ទីរវប្បធម៌ និង វិចិត្រ-សិល្បៈ ខេត្តកណ្តាល |
| ៤-កញ្ញា | **មួង សារឹម** | ប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក មន្ទីរវប្បធម៌ និង វិចិត្រ-សិល្បៈ ខេត្តកណ្តាល |
| ៥-លោក | **ផា សុខែម** | ប្រធានការិយាល័យវប្បធម៌ និង វិចិត្រសិល្បៈ ស្រុកពញាឮ |

**ខ_មេដាយប្រាក់ការងារ :**

| | | |
|---|---|---|
| ១-លោក | **ម៉ីន សាម៉ុន** | អនុប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកណ្តាល |
| ២-កញ្ញា | **គីម ណារី** | អនុប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកណ្តាល |

៣-លោក **ម៉ន សាមន** អនុប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកណ្តាល

៤-លោក **យ៉េ យ៉ុង** អនុប្រធានការិយាល័យ បេតិកភណ្ឌ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកណ្តាល

៥-លោក **សោម សុវណ្ណ** ប្រធានការិយាល័យ វប្បធម៌ និង វិចិត្រសិល្បៈ ស្រុកតាខ្មៅ

៦-លោក **ម៉ែន ញ៉ឹល** ប្រធានការិយាល័យ វប្បធម៌ និង វិចិត្រសិល្បៈ ស្រុកកៀនស្វាយ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៥១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## ស ំ រេ ច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន០៣រូប នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកណ្តាល ដែលមានស្នាដៃល្អឆ្នើម ក្នុងការស្តារ និងអភិវឌ្ឍន៍ វិស័យសិល្បៈវប្បធម៌ជាតិ រយៈពេល៥ឆ្នាំ " ១៩៩៩-២០០៣ " ដូចមានរាយនាមខាងក្រោមនេះ :-

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :**

-លោក **សុខ អឿន** ប្រធានមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកណ្តាល

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :**

១-លោក **សុក ម៉ុនថុន** អនុប្រធានមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកណ្តាល

២-លោក **អៀ សុខា** អនុប្រធានមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកណ្តាល

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៥២ អនក្រ-តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

### សំរេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងបង្ហើយព្រះវិហារ វត្តព្រះជីរ ឃុំជីរពូន ស្រុកព្រៃវែង ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **ស៊ុខ ផេង** និងអ្នកស្រី **ម៉ៅ ជូ** | ថវិកាចំនួន | ២០.៣១១.០០០រៀល និង ៥.២៥០ USD |
| ២-លោក | **អ៊ុំន ម៉ុត** និងអ្នកស្រី **ឡៀម ឈាន** | ថវិកាចំនួន | ១២.០០០ USD |

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| -អ្នកស្រី | **ជីវ មួយ** នៅសហរដ្ឋអាមេរិក | ថវិកាចំនួន | ២.២២០ USD |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

70

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៥ អនក្រ.បក -៩៩

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

**សំរេច**

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគថវិកាជួយកសាងបង្ហើយព្រះវិហារ វត្តត្រពាំងប្រីយ៍ ឃុំត្របែក ស្រុកកំចាយមារ ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោមនេះ :-

**ក.មេដាយមាសស្ថាបនាជាតិ :**

១-លោកយាយឧបាសិកា **ឡុន យី** ថវិកា ចំនួន ៤០.០០០.០០០ រៀល

២-លោក **មាស សឿន** និង លោកស្រី **កើត សាវ៉ាន** ថវិកា ចំនួន ១០.២៥៦ ដុល្លារ

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក **ម៉ិន សំអុល** និងអ្នកស្រី ថវិកា ចំនួន ៣០.០០០.០០០ រៀល

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៣ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៥៤ [illegible]

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជូននាយនគរបាលជាតិ ជាជំនួយការឯកឧត្តមឧត្តមសេនីយ៍-ឯក **យ៉េង ម៉ារឌី** អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោកវរៈសេនីយ៍ទោ **តឹក ញាណ** អត្តលេខ ០៩៤៤ ជំនួយការ ។

២-លោកវរៈសេនីយ៍ទោ **ឆាង សារិត** អត្តលេខ ០៩៤៥ ជំនួយការ ។

៣-លោកវរៈសេនីយ៍ទោ **នុត សេងខួន** អត្តលេខ ០៩៤៦ ជំនួយការ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៥៥ អនក្រ-តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជូននាយនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោកវរៈសេនីយ៍ទោ **ព្រហ្ម ជាន** អត្តលេខ ០៥០៦ អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ។
២-លោកវរៈសេនីយ៍ទោ **ញឹក ស៊ីផន** អត្តលេខ ០៥១១ អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១[illegible] ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១៥៦ សហវ

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៣

# ប្រកាសអន្តរក្រសួង
# ស្តីពីការបង្កើតវិជ្ជាបនបុរេប្រទាន
# នៅទីស្តីការគណៈរដ្ឋមន្ត្រី

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស/៩៣ ចុះ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ សនួ/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់វិសោធនកម្មមាត្រា

២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ០០៤ សហវ-មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញលិខិតលេខ ១១៥ សហវ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញសារាចរណែនាំលេខ ០០៣ សហវ.ម ចុះថ្ងៃទី ១៩ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរដ្ឋទេយ្យបុរេប្រទាន

-បានឃើញប្រកាសលេខ ១២៩ ប្រក-សហវ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៧ ស្តីពីការកំណត់ទឹកប្រាក់រដ្ឋទេយ្យបុរេប្រទានជំពូក ១១ សំរាប់ទូទាត់ចំណាយចាំបាច់លើដំណើការរដ្ឋបាល សំភារៈ និងការជួសជុលតូច

-បានឃើញតំរូវការចាំបាច់នៃការងារ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ បច្ចុប្បន្ន

## សំរេច

**ប្រការ ១:**

-ត្រូវបានបង្កើតរដ្ឋទេយ្យបុរេប្រទានជំពូក ៣០ នៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បី ធ្វើការទូទាត់ការចំណាយទាំងឡាយដែល មានចែងក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។ ចំនួនទឹកប្រាក់ជាអតិបរមានៃ ការចំណាយ ដែលអនុញ្ញាតអោយរដ្ឋទេយ្យករបុរេប្រទានធ្វើការទូទាត់ត្រូវបានកំណត់ក្រោម **៥០០.០០០៛០០** ( ប្រាំរយពាន់ រៀលគត់ )តាមចំណាត់ថ្នាក់ទីមួយ១ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយ នឹង ប្រកាសអន្តរក្រសួង ។

**ប្រការ ២:**

-ចំនួនទឹកប្រាក់នៃរដ្ឋទេយ្យបុរេប្រទានជំពូក ៣០ សំរាប់មួយជុំនៃឆ្នាំត្រូវបានកំណត់ត្រឹមចំនួន **២៦២.៥០០.០០០៛០០** ( ពីររយហុកសិបពីរលាន ប្រាំរយពាន់ រៀលគត់ ) ។

**ប្រការ ៣:**

-សេចក្តីសំរេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤:**

-អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានថវិកា នីយកម្ម និង ហិរញ្ញកិច្ច ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឪវាទ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនិង ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះចាប់ពី ថ្ងៃ ចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ទេសរដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

<u>កន្លែងទទួល</u>

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៤
"ដើម្បីមុខការ"
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ**
**បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

លេខ ០៤ សរណន.សកបុយ រាជធានីភ្នំពេញ . ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៣

# សារាចរណែនាំអនុវត្ត

## អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីការកែសំរួល ការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធបៀវត្សថ្មី

ដើម្បីអនុវត្តតាមមាត្រា២ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីការកែសំរួលការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមធ្វើការណែនាំអំពីរបៀបគិតប្រាក់សោធន ដូចខាងក្រោម ៖

**ក- របៀបគិតប្រាក់សោធនតាមបៀវត្សចាស់ ទៅជាប្រាក់សោធនគិតតាមបៀវត្សមូលដ្ឋាន ៖**

១- ប្រាក់សោធនគិតតាមបៀវត្សមូលដ្ឋាន ខ្ពស់ជាងប្រាក់សោធនគិតតាមបៀវត្សចាស់ ៖

ឧទាហរណ៍ទី១ ៖ បុគ្គលិកម្នាក់បានចូលនិវត្តន៍ នៅថ្ងៃទី០១ ខែ តុលា ឆ្នាំ ១៩៩០ មុនពេលចូលនិវត្តន៍គាត់មានអតីតភាពការងាររួម ៣៨ ឆ្នាំ ដែលក្នុងនោះមាន១១ឆ្នាំក្នុងរបបវដ្តកម្ពុជា និងមានតារាងកាំប្រាក់ ខ III ៦ = ៣៣ ៤០០ ៛០០ គាត់ទទួលបានប្រាក់សោធននិវត្តន៍ប្រចាំខែចំនួន ៤០ ២៨០ ៛៤០ រហូតដល់ថ្ងៃទី០១.០១.០២។ ក្នុងករណីនេះ ការគណនាប្រាក់សោធននិវត្តន៍តាមបៀវត្សមូលដ្ឋាន មានដូចខាងក្រោម ៖

- តារាងកាំប្រាក់ ខ III ៦ = ៣៣ ៤០០ ៛០០ ត្រូវបានធ្វើសមាហរណកម្មទៅជាបៀវត្សមូលដ្ឋាន គ ៣.៩ = ៥២ ២០០ ៛០០

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ៖ $\frac{៥២\ ២០០\ ៛០០ \times ៨០}{១០០}$ = ៤១ ៧៦០ ៛០០

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ៤១ ៧៦០ ៛០០ ត្រូវតម្លើងអោយស្មើប្រាក់បៀវត្សមូលដ្ឋានអប្បបរមាប្រចាំខែរបស់សាមីជន គ ៣.១៤ = ៤៥ ០០០ ៛០០

- ដូច្នេះប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ = ៤៥ ០០០ ៛០០

ឧទាហរណ៍ទី២ : មន្ត្រីម្នាក់បានចូលនិវត្តន៍នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៨ មុនពេលចូលនិវត្តន៍គាត់មានអតីតភាពការងាររួម ៣៥ ឆ្នាំ និងមានតារាងកាំប្រាក់ គ II ៧.២ = ៤០ ៦០០ រ៛០០ ហើយគាត់ទទួលបានប្រាក់សោធននិវត្តន៍ប្រចាំខែចំនួន ៦៧ ៤២០ រ៛០០ រហូតដល់ថ្ងៃទី ០១.០១.០២ ។ ក្នុងករណីនេះ ការគណនាប្រាក់សោធននិវត្តន៍តាមបៀវត្សមូលដ្ឋាន មានដូចខាងក្រោម :

- តារាងកាំប្រាក់ គ II ៧.២ = ៤០ ៦០០ រ៛០០ ត្រូវបានធ្វើសមាហរណកម្មទៅជាបៀវត្សមូលដ្ឋាន ក ៣.៥ = ១១៩ ៧០០ រ៛០០ ( ៣០០ x ៣៩៩ )
- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ : $\frac{១១៩\ ៧០០\ រ៛០០ \times ៨០}{១០០}$ = ៩៥ ៧៦០ រ៛០០

ឧទាហរណ៍ទី៣ : មន្ត្រីម្នាក់បានចូលនិវត្តន៍នៅថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៨ មុនពេលចូលនិវត្តន៍គាត់មានអតីតភាពការងាររួម ៣៥ ឆ្នាំ និងមានតារាងកាំប្រាក់ គ II ២ = ២៦ ៤០០ រ៛០០ ហើយគាត់ទទួលបានប្រាក់សោធននិវត្តន៍ប្រចាំខែចំនួន ៤២ ៤៨០ រ៛០០ រហូតដល់ថ្ងៃទី ០១.០១.០២ ។ ក្នុងករណីនេះ ការគណនាប្រាក់សោធននិវត្តន៍តាមបៀវត្សមូលដ្ឋាន មានដូចខាងក្រោម :

- តារាងកាំប្រាក់ គ II ២ = ២៦ ៤០០ រ៛០០ ត្រូវបានធ្វើសមាហរណកម្មទៅជាបៀវត្សមូលដ្ឋាន ឃ ១.៥ = ៤៤ ៧០០ រ៛០០ និង មានប្រាក់បង្គ្រប់ ២ ២០០ រ៛០០
- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ : $\frac{៤៤\ ៧០០\ រ៛០០ \times ៨០}{១០០}$ = ៣៥ ៧៦០ រ៛០០
- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ៣៥ ៧៦០ រ៛០០ ត្រូវតម្លើងអោយស្មើប្រាក់បៀវត្សមូលដ្ឋានអប្បបរមា របស់សាមីជន ឃ ១.៦ = ៤២ ៣០០ រ៛០០
- បូកបន្ថែមប្រាក់បង្គ្រប់ = ២ ២០០ រ៛០០
- ដូច្នេះប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ = ៤៤ ៥០០ រ៛០០

២- ប្រាក់សោធនគិតតាមបៀវត្សមូលដ្ឋាន ទាបជាងប្រាក់សោធនគិតតាមបៀវត្សចាស់ :

ឧទាហរណ៍ : មន្ត្រីម្នាក់បានចូលនិវត្តន៍នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០១ មុនពេលចូលនិវត្តន៍គាត់មានអតីតភាពការងាររួម ៣៣ ឆ្នាំ និងមានតារាងកាំប្រាក់ គ I ៣ = ៣១ ៤០០ រ៛០០ ហើយគាត់ទទួលបានប្រាក់សោធននិវត្តន៍ប្រចាំខែចំនួន ៤៨ ៣៨០ រ៛០០ រហូតដល់ថ្ងៃទី ០១.០១.០២ ។ ក្នុងករណីនេះ ការគណនាប្រាក់សោធននិវត្តន៍តាមបៀវត្សមូលដ្ឋាន មានដូចខាងក្រោម :

- តារាងកាំប្រាក់ គ I ៣ = ៣១ ៤០០ រ៛០០ ត្រូវបានធ្វើសមាហរណកម្មទៅជាបៀវត្សមូលដ្ឋាន គ ៣.១០ = ៥០ ៤០០ រ៛០០

៩០ ៤០០ ៛០០ x ៨០

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ : ―――――――――― = ៤០ ៣២០ ៛០០

១០០

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ៤០ ៣២០ ៛០០ ត្រូវតម្លើងអោយស្មើប្រាក់បៀវត្សមូលដ្ឋានអប្បបរមារបស់សាមីជន គ :៣.១៤. = ៤៥ ០០០ ៛០០
- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែគិតតាមបៀវត្សមូលដ្ឋាននេះ ទាបជាងប្រាក់សោធននិវត្តន៍គិតតាមបៀវត្សចាស់ ។ ក្នុងករណីនេះ ត្រូវតម្លើងឱ្យស្មើប្រាក់សោធននិវត្តន៍គិតតាមបៀវត្សចាស់វិញ = ៤៨ ៣៨០ ៛០០
- ដូច្នេះប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ = ៤៨ ៣៨០ ៛០០

\+ **កំណត់សំគាល់ :** ការគណនាប្រាក់សោធននិវត្តន៍តាមបៀវត្សមូលដ្ឋាន បើមានករណីទាបជាងប្រាក់សោធននិវត្តន៍គិតតាមបៀវត្សចាស់ ត្រូវតម្លើងឱ្យស្មើដូចករណីខាងលើនេះដែរ ។

៣- ការគណនាប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ មានរបៀបគិតដូចប្រាក់សោធននិវត្តន៍ដែរ ប៉ុន្តែមិនត្រូវទាបជាង ៩០ ភាគរយ នៃបៀវត្សមូលដ្ឋានអប្បបរមារបស់សាមីជនឡើយ ។

៤- ការគណនារយៈពេលបំពេញការងារ ៥ ឆ្នាំក្នុងរបបរដ្ឋកម្ពុជា ត្រូវបានអនុវត្តដូចរយៈពេលបំពេញការងារ ២០ ឆ្នាំ ដែលមានចែងក្នុងអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល ។

**ខ. ភារកិច្ចរបស់ក្រសួង ស្ថាប័ន :**

សំណុំលិខិតចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ របស់ក្រសួង ស្ថាប័ននីមួយៗ ត្រូវអនុវត្តតាមមាត្រាទី៦ នៃ អនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលអោយចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធពតិមានវិទ្យា និងអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ ស្តីពីការកែសំរួលការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធបៀវត្សមូលដ្ឋាន ។

**គ. ភារកិច្ចរបស់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត ក្រុង :**

មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវធ្វើលិខិតស្នើសុំផ្ទេរប្រាក់សោធនប្រចាំខែរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ មកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដោយភ្ជាប់មកជាមួយនូវ :

- សៀវភៅនិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ

- តារាងបើកប្រាក់សោធនប្រចាំខែចុងក្រោយ ចំនួន ០១ ច្បាប់
- តារាងគណនាប្រាក់សោធនគិតតាមបៀវត្សមូលដ្ឋាន និងប្រាក់សោធនគិតតាមបៀវត្សចាស់ ដូចមានគំរូជូនភ្ជាប់ ចំនួន ០១ ច្បាប់

សារាចរណែនាំនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាបជាព័ត៌មាន"

- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត ក្រុង

"ដើម្បីសហការអនុវត្ត"

- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន
លេខ: 123 ប្រក.សក.បច

ភ្នំពេញ, ថ្ងៃទី 21 ខែ 03 ឆ្នាំ ២០០៣

# ប្រកាស

## ស្ដីពីការដាក់អោយសាលាបច្ចេកទេស ហ៊ី វ៉ សេ ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

## រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០.១១.១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន ។
- បានឃើញ អនុក្រឹត្យលេខ ១៤/អនក្រ.បក ចុះថ្ងៃទី ០៣.០៣.១៩៩៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។
- យោងលិខិតលេខ ១៩៤៤.សជណ ចុះថ្ងៃទី ២២.១២.២០០០ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពីសំណើសុំលក់អចលនទ្រព្យរបស់ក្រុមហ៊ុនដឹកជញ្ជូនដោយរថយន្ត ចំនួនប្រាំកន្លែង ដែលមានក្រុមហ៊ុន សូគីមិច ជាអ្នកទិញ ។
- យោងលិខិតលេខ ០០៣/មស.ក្រខ ចុះថ្ងៃទី ០៨.០១.២០០៣ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្ដីពីសំណើសុំបញ្ចូលក្របខ័ណ្ឌមន្ត្រី-រាជការ ចំនួន ៣១ រូប ពីក្រុមហ៊ុនដឹកជញ្ជូន ដោយរថយន្ត មកក្នុងក្របខ័ណ្ឌបុព្វហេតុរដ្ឋបាល នៃ ក្រសួងសាធារណការ និង ដឹកជញ្ជូន ។
- យោងកិច្ចព្រមព្រៀងរវាងក្រសួងសាធារណការ និង ដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងអង្គការស្ម័គ្រចិត្តអន្តរជាតិនៃប្រទេសជប៉ុន J V C ។
- យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

## សម្រេច

**ប្រការ ១ :** ត្រូវបានផ្ទេរការងារគ្រប់គ្រងសាលាបច្ចេកទេស ហ៊ី វ៉ សេ នៃ ក្រុមហ៊ុនដឹកជញ្ជូនដោយរថយន្ត អោយមកស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

**ប្រការ ២ :** ការរៀបចំ និង ការប្រព្រឹត្តទៅរបស់សាលាបច្ចេកទេស ហ៊ី វ៉ សេ នឹងត្រូវកំណត់ដោយបទដ្ឋានដោយឡែក ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ, អគ្គនាយក នៃ អគ្គនាយកដ្ឋានរដ្ឋបាល, អគ្គនាយក នៃ អគ្គនាយកដ្ឋានសាធារណការ អគ្គនាយក នៃ អគ្គនាយកដ្ឋានដឹកជញ្ជូន និង អគ្គាធិការ នៃ អគ្គាធិការដ្ឋាន ត្រូវទទួលបន្ទុកអនុវត្តរៀង១ខ្លួន តាមខ្លឹមសារ នៃ ប្រកាសនេះដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ខឹម តាំងលីម

**កន្លែងទទួល :**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

**ដើម្បីជូនជ្រាបជាពត៌មាន**
- ដូចប្រការ ៣

**ដើម្បីអនុវត្ត**
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
លេខ:......[illegible]......

រាជធានីភ្នំពេញ,ថ្ងៃទី..១៧..ខែ..មិនា...ឆ្នាំ ២០០៣.

# ប្រ កា ស

## ស្តីពី
## ការកំណត់និមិត្តសញ្ញាក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

-----------------------

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស.រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស.រកម ០១៩៦-០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងវប្បធម៌ នឹងវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងវប្បធម៌ នឹង វិចិត្រសិល្បៈ
- យោងស្មារតីទិវាវប្បធម៌ជាតិលើកទី ១ ០៣-មេសា-១៩៩៨

## សំ រេ ច

**ប្រការ១ :** ត្រូវបានកំណត់និមិត្តសញ្ញាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយរូបព្រះកេសព្រះបាទជ័យវរ្ម័នទី ៧ ។

**ប្រការ២ :** លក្ខណៈ និង អត្ថន័យរបស់និមិត្តសញ្ញាមាន :

- ព្រះកេសព្រះបាទជ័យវរ្ម័នទី ៧ ពណ៌ទឹកមាសស្រអាប់នៅចំកណ្តាលតំណាងឱ្យបញ្ញាញាណ ឧត្តមគតិ ភាពវៃឆ្លាត និងភាពទទួលខុសត្រូវក្នុងការដឹកនាំប្រទេសរបស់ថ្នាក់ដឹកនាំខ្មែរ
- កម្រងផ្កាឈូកទ្រព្រះកេសព្រះបាទជ័យវរ្ម័នទី ៧ ពណ៌ទឹកមាសថ្លា តំណាងឱ្យភាពល្អបរិសុទ្ធនៃព្រះពុទ្ធសាសនា រួមនិងការបង្កើតឡើងនូវលទ្ធិពុទ្ធរាជា ក្នុងការគ្រប់គ្រងប្រទេសរបស់វីរៈមហាក្សត្រខ្មែរ
- ផែនដីនៅពីក្រោមកម្រងផ្កាឈូករាងឆ្កូត ៤ ត្រឹមពាក់កណ្តាល ខាងក្រោមមានស្នាមអង្កាញ់ជាទឹករលកពណ៌ ទឹកមាសស្រអាប់តំណាងឱ្យភពផែនដី និងធាតុទាំង៤ គឺ ទឹក ដី ភ្លើង ខ្យល់ ដែលជាលោកធាតុផ្តល់នូវកំណើត មនុស្ស និងធម្មជាតិ
- ត្រីសូលិ៍ដែលនៅពីក្រោមជាប់និងផែនដីពណ៌ទឹកមាសស្រអាប់ផ្ទៃក្នុងថ្លា តំណាងឱ្យបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ និងតំណាងឱ្យព្រហ្មញ្ញសាសនា និងពុទ្ធសាសនាដែលស្ថិតនៅរួមជាមួយគ្នាក្នុងជំនឿរបស់ប្រជាជន កម្ពុជា
- ក្បាច់ផ្កាដូងដែលមានរាងជារង្វង់អមសងខាងរូបព្រះកេសព្រះបាទជ័យវរ្ម័នទី ៧ ពណ៌ទឹកមាសស្រអាប់ តំណាង ឱ្យភោគផលកសិកម្មដ៏សំបូរហូរហៀរ ដែលសបញ្ជាក់ឱ្យឃើញនូវភាពឧស្សាហ៍ព្យាយាមរបស់បុព្វបុរសខ្មែរដែល បានកសាងទឹកដីឱ្យសម្បូររុងរឿង

- ពណ៌ទឹកមាសខ្ចី និងស្រអាប់ គឺតំណាងឱ្យសញ្ញាសង្គ្រោះដល់វប្បធម៌ អារ្យធម៌ខ្មែរ និងប្រជាពលរដ្ឋខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជា
- ឈ្មោះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនៅផ្ទៃខាងក្រោម ដោយមានពាក្យក្រសួងនៅចំកណ្តាលផ្ទៃទី ១ ហើយពាក្យវប្បធម៌ និងវិចិត្រសិល្បៈនៅផ្ទៃទី ២ អមសងខាងសរសេរជាអក្សរពណ៌ស្វៃ ដែលតំណាងឱ្យបរិស្ថានធម្មជាតិដ៏ស្រស់បំព្រងនៃទឹកដីកម្ពុជា រួមនិងក្តីសង្ឃឹមលើសាមគ្គីឯកភាពជាតិ របស់ប្រជាជនខ្មែរក្នុងការលើកស្ទួយវប្បធម៌ជាតិឱ្យរីកចំរើនខ្ពង់ខ្ពស់ឡើងវិញ ។

**ប្រការ៣ :** និមិត្តសញ្ញានេះត្រូវបានកំណត់ឱ្យប្រើប្រាស់នៅលើ :

- លិខិតបទដ្ឋាន រដ្ឋបាល និងស្រោមសំបុត្រ "ផ្លូវការ" របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- ប័ណ្ណសំគាល់ខ្លួនមន្ត្រីរាជការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- លិខិត ប័ណ្ណ ( សរសើរ ឬ កិត្តិយស ) របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- សញ្ញាប័ត្រ វិញ្ញាបនប័ត្រ លិខិតបញ្ជាក់ផ្សេងៗ ចេញដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- នាមប័ណ្ណរបស់ថ្នាក់ដឹកនាំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ( ចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើង ) ។

**ប្រការ៤ :** មិនត្រូវបានអនុញ្ញាតឱ្យយកនិមិត្តសញ្ញានេះទៅប្រើប្រាស់ក្នុងលក្ខណៈក្រៅផ្លូវការ ឬឯកជន ខុសពីខ្លឹមសារដែលបានកំណត់ក្នុងប្រការ ៣ ។

**ប្រការ៥ :** ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អធិការដ្ឋាន គ្រប់អង្គភាពចំណុះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង មានភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី ✓
- ក្រសួងមហាផ្ទៃ
  "ដើម្បីជ្រាបជាពត៌មាន"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះអង្គម្ចាស់ - ស៊ីសុវត្ថិ